**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិ និងតួនាទីរបស់មេធាវីក្នុងសាលាជម្រះក្តីជាន់ទាប

ស្រាវជ្រាវពីថ្ងៃទី ២៧ មេសា ២០២១ ដល់ថ្ងៃទី ២៥ មិថុនា ២០២១

តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **រ៉ុន ឆៃហេង**

**ឡៅ តាយហេង**

សាស្ត្រាចារ្យណែនាំ

**លោក ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

បឋមយើងខ្ញុំទាំងពីរនាក់ឈ្មោះ **រ៉ុន នៃហេង** និង **ឡៅ គាយហេង** (ក្រុមL4C2) ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០២១។

## យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

**លោកឪពុក** និង **អ្នកម្តាយ**ជាទីគោរព ដែលមាននូវមហាឧបការគុណដ៏ឧត្តុងឧត្តម និងធំធេងបំផុតគ្មានអ្វីប្រៀបផ្ទឹម និងមិនអាចបំភ្លេចបានឡើយ ព្រោះលោកទាំងពីរជាអ្នកមានគុណដោយបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅ ព្រមទាំងទំនុកបម្រុងសព្វសារពើទាំងអស់ឱ្យកូនតាំងពីតូចរហូតដល់ធំ ហើយលោកទាំងពីរបានអប់រំ ណែនាំ និងទូន្មានប្រៀនប្រដៅកូនឱ្យចេះដឹងខុសត្រូវធ្វើជាមនុស្សល្អនៅក្នុងសង្គម។ ក្រៅពីនេះ លោកទាំងពីរក៏បានជំរុញទឹកចិត្តឱ្យកូនខិតខំសិក្សារៀនសូត្រដោយបានបញ្ជូនកូនទៅរៀននៅសាលារៀន ព្រមទាំងឧបត្ថម្ភកូនគ្រប់បែបយ៉ាង ទាំងកម្លាំងកាយ កម្លាំងចិត្ត និងសម្ភារៈរហូតដល់កូនរៀនចប់ដោយជោគជ័យ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការដឹកនាំ គ្រប់គ្រង ជ្រោមជ្រែង និងបង្ហាត់បង្រៀនយើងខ្ញុំឱ្យទទួលបាននូវចំណេះដឹងយ៉ាងច្រើនកន្លងមក។

**លោកសាស្ត្រាចារ្យ ទេព សុខ** ដែលជាសាស្ត្រាចារ្យណែនាំ ដោយលោកបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងផ្តល់ឯកសារមួយចំនួន ព្រមទាំងជួយកែតម្រូវយ៉ាងយកចិត្តទុកដាក់បំផុតរហូតបានធ្វើឱ្យសារណាមួយនេះបានលេចចេញជារូបរាង។

សូមអរគុណដោយស្មោះស្ម័គ្រ និងមោទនភាពជាតិចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំ ដែលបាននឹងកំពុងដឹកនាំ ប្រទេសកម្ពុជាលើផ្លូវនយោបាយដ៏ត្រឹមត្រូវមួយប្រកបដោយសុច្ចរិតភាព រក្សាបាននូវសុខសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍ ហើយដែលជាការផ្តល់ឱកាសយ៉ាងប្រសើរ សម្រាប់ការសិក្សារ និងការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនាពេលនេះ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរ សូមសម្តែងសេចក្តីគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជាពិសេសសូមប្រសិទ្ធពរជ័យ សិរីសួរស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងឡាយទទួលបានជោគជ័យគ្រប់ភារកិច្ច និងសុខភាពរឹងមាំទទួលទានគ្រប់ៗគ្នា ព្រមទាំងពុទ្ធពរទាំងប្រាំប្រការទៀតគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅដែលលោកអ្នកកំពុងតែកាន់អាននេះគឺជាវណ្ណកម្មរបស់យើងខ្ញុំផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលក្រុមរបស់យើងខ្ញុំបានខិតខំព្យាយាមស្រាវជ្រាវសរសេរឡើង ដើម្បីទុកជាចំណងដៃសម្រាប់អស់លោកអ្នក ដែលការព្យាយាមសរសេរនេះគឺក្រុមយើងខ្ញុំយល់ឃើញថាសៀវភៅ ក្បួនច្បាប់ផ្សេងៗ ផ្នែកសីលធម៌នៅក្នុងសង្គមរបស់ប្រទេសកម្ពុជាយើងដែលបានបាត់បង់ជាច្រើននៅពេលប្រទេសយើងជួបវិបត្តិ។ ពេលនោះគឺជាកំឡុងពេលដ៏អាក្រក់ដែលសៀវភៅក្បួនច្បាប់ផ្សេងៗដែលជាស្នាដៃរបស់អ្នកនិពន្ធរៀមច្បងយើងខិតខំបង្កើតឡើងដើម្បីទុកឲ្យយើងដែលជាជាតិខ្មែរជំនាន់ក្រោយសម្រាប់រៀនសូត្រត្រូវបានបំផ្លាញ។ ឥឡូវនេះក្រុមយើងខ្ញុំមានកាលានុវត្តភាព ជួបជាមួយអស់លោកអ្នកតាមរយៈសំណេររបស់ក្រុមយើងខ្ញុំទុកជាចំណងដៃសម្រាប់លោកអ្នកអានក្នុងសហស្សវត្សថ្មីនេះ។ ហើយម្យ៉ាងទៀត កម្រងឯកសារដែលបានលើកឡើងក្នុងអត្ថបទដែលមិត្តនិស្សិត លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ កំពុងតែអាននេះមានចំណងជើងជាខេមរភាសាថា “**សិទ្ធិ និងតួនាទីរបស់មេធាវីក្នុងសាលាជម្រះក្តីជាន់ទាប**។

យើងខ្ញុំសង្ឃឹម និងជឿជាក់ថានៅក្នុងការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនេះទោះបីជាមានការខិតខំព្យាយាមពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយក៏នៅតែមានភ្លាំងភ្លាត់ខុសឆ្គងខ្លះៗដោយអចេតនាពុំខាន។ បើដូច្នេះយើងខ្ញុំសូមអភ័យទោសអំពីសំណាក់អស់លោកមិត្តអ្នកអានទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងឡាយដែលអាចកើតមានដោយចេតនាក្តី អចេតនាក្តី និងសូមខន្តីអភ័យទោសដោយការគោរពយ៉ាងស្មោះស្ម័គ្រពីសំណាក់ក្រុមរបស់យើងខ្ញុំ ហើយក៏ទទួលស្វាគមន៍នូវរាល់ការរិះគន់បែបស្ថាបនាដើម្បីកែលំអព្រមទាំងបន្ថែមនូវគំនិតល្អៗដើម្បីបន្សល់ទុកឲ្យកូនខ្មែរជំនាន់ក្រោយក្នុងការសិក្សា។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរដល់មិត្តអ្នកអានទាំងអស់ ដែលជាក្រុមនិស្សិត លោកគ្រូ អ្នកគ្រូក៏ដូចជាប្រជាពលរដ្ឋខ្មែរគ្រប់រូបឲ្យជួបប្រទះតែសំណាង សុខភាពល្អ និងទទួលបាននូវជោគជ័យនៅក្នុងជីវិតគ្រប់ភារកិច្ច។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................................................ ១
ជំពូកទី១ សញ្ញាណគតិយុត្តនៃមេធាវីនៅកម្ពុជា ........................................ ៣
១.ប្រវត្តិសាស្ត្រនៃការវិវត្តវិជ្ជាជីវៈមេធាវីនៅកម្ពុជា ........................................ ៣
២.លិខិតបទដ្ឋានទាក់ទងនឹងមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ........................ ៥
២.១. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ........................................................ ៥
២.១.១. នីតិវិធីការចូលប្រកបវិជ្ជាជីវៈ ........................................................ ៦
ក. តាមរយៈការប្រឡង ........................................................ ៦
ក.១. លក្ខខណ្ឌ ........................................................ ៦
ក.២. ការប្រឡង ........................................................ ៧
ក.៣. ការចុះកម្មសិក្សា ........................................................ ៧
ខ. តាមការស្នើសុំ ........................................................ ៧
ខ.១. លក្ខខណ្ឌ ........................................................ ៧
ខ.២. ការដាក់ពាក្យសុំ ........................................................ ៨
ខ.៣. ការដាក់ពាក្យធ្វើកម្មសិក្សា ........................................................ ៨
២.២. ក្រមសីលធម៌វិជ្ជាជីវៈមេធាវី (ការប្រកបវិជ្ជាជីវៈ) ........................................ ៩
២.២.១. ឯករាជ្យភាព និងសេរីភាព នៃវិជ្ជាជីវៈមេធាវី ........................................ ៩
២.២.២. តម្លៃសីលធម៌នៃវិជ្ជាជីវៈមេធាវី ........................................................ ១០
ក. សញ្ញាណទូទៅ ........................................................ ១០
ខ. ការទទួលរឿងក្តី ........................................................ ១០
គ. ការប្រុងប្រយ័ត្ន ........................................................ ១០
ឃ. សុចរិតភាព និងភាពស្មោះត្រង់ ........................................................ ១១
ង. ការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ........................................................ ១១
ច. ទំនាស់ផលប្រយោជន៍ និងការហាមឃាត់ ........................................................ ១២
២.២.៣. ការបង់វិភាគទាន ........................................................ ១៣

ជំពូកទី២ សិទ្ធិ និងតួនាទីរបស់មេធាវីក្នុងសាលាជម្រះក្តីជាន់ទាប ................................ ១៤
ផ្នែកទី១ សិទ្ធិរបស់មេធាវីក្នុងសាលាជម្រះក្តីកម្ពុជា ................................ ១៤
១. សិទ្ធិក្នុងការបំពេញមុខងារវិជ្ជាជីវៈដោយគ្មានការរៀតត្បៀត ................................ ១៤
២. សិទ្ធិទទួលបានការការពារ ................................ ១៥
៣. សិទ្ធិទទួលបានអភ័យឯកសិទ្ធិរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ................................ ១៥
៤. សិទ្ធិក្នុងការតំណាងកូនក្តី ................................ ១៦
៥. សិទ្ធិទទួលបានកូនក្តី និងពត៌មានសម្រាប់ការពារកូនក្តី ................................ ១៦
៦.សិទ្ធិមិនត្រូវសំដែងមានចិត្តជាមួយកូនក្តី ឬបុព្វហេតុរបស់កូនក្តី ................................ ១៧
៧.សិទ្ធិក្នុងការទទួលបានការសំខាន់ផ្នែកវិជ្ជាជីវៈមេធាវី ................................ ១៧
៨.សិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគមន៍ ................................ ១៨
៩.សិទ្ធទទួលបានការអប់រំ និងការបណ្តុះបណ្តាល ................................ ១៨
១០.មេធាវីមានសិទ្ធិទទួលបានមេធាវីម្នាក់ទៀតដើម្បីផ្តល់ជាជំនួយដល់ខ្លួន ................................ ១៩
១១.សិទ្ធិទទួលបានការផ្តល់ពត៌មានសម្រាប់កូនក្តីរបស់ខ្លួន ................................ ១៩
ផ្នែកទី២ តួនាទីរបស់មេធាវីក្នុងសាលាជម្រះក្តីជាន់ទាប ................................ ២០
១. តួនាទីក្នុងរឿងក្តីព្រហ្មទណ្ឌ ................................ ២០
១.១. តួនាទីរបស់មេធាវីមុនពេលជំនុំជម្រះ ................................ ២០
១.១.១. ការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌ ................................ ២០
១.១.២. ការចោទប្រកាន់ និង ស៊ើបអង្កេត ................................ ២៣
១.១.៣. ការស៊ើបសួរ ................................ ២៣
ក. ការសួរចម្លើយ និង ការស្តាប់ចម្លើយ ................................ ២៤
ក.១. ការសួរចម្លើយជនត្រូវចោទ ................................ ២៤
ក.២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ................................ ២៤
ក.៣. ការស្តាប់ចម្លើយសាក្សី ................................ ២៥
ខ. ការធ្វើកោសលវិច្ច័យ ................................ ២៦
គ. ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌ ................................ ២៦
ឃ. ការឃុំខ្លួនបណ្តោះអាសន្ន ................................ ២៧
១.២. តួនាទីរបស់មេធាវីអំឡុងពេលជំនុំជម្រះ ................................ ២៧

១.២.១. បញ្ហា និង អង្គហេតុ ............ ២៨
១.២.២. ការពិភាក្សាដេញដោល ............ ២៨
១.២.៣. ការបង្ហាញភស្តុតាង ............ ២៩
១.២.៤. ពេលសន្និដ្ឋានការពារ ............ ៣០
១.៣. តួនាទីមេធាវី ក្រោយបញ្ចប់ពេលជំនុំជម្រះ ............ ៣១
ក. បណ្ដឹងទៅតុលាការជាន់ខ្ពស់ ............ ៣១
ក.១.បណ្ដឹងឧទ្ធរណ៍ ............ ៣១
ក.២.បណ្ដឹងឧទ្ធរណ៍ ............ ៣១
ក.៣.បណ្ដឹងសារទុក្ខ ............ ៣២
ក.៤.បណ្ដឹងសើរើ ............ ៣២
២. តួនាទីក្នុងរឿងក្ដីរដ្ឋប្បវេណី ............ ៣២
២.១.តួនាទីរបស់មេធាវី មុនពេលជំនុំជម្រះ ............ ៣៣
២.១.១ តួនាទីរបស់មេធាវី ក្នុងនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ ............ ៣៤
ក. តួនាទីរៀបចំដាក់ឯកសារត្រៀម ............ ៣៤
ខ. តួនាទីផ្សះផ្សាដោយមេធាវី ............ ៣៥
គ. តួនាទីក្នុងការធ្វើសេចក្ដីថ្លែងការណ៍ ............ ៣៥
ឃ. តួនាទីក្នុងការបំភ្លឺចំណុចវិវាទ ............ ៣៦
ង. តួនាទីស្នើសុំតុលាការក្នុងការពិនិត្យភស្តុតាង ............ ៣៦
២.២. តួនាទីរបស់មេធាវី អំឡុងពេលជំនុំជម្រះ ............ ៣៧
២.២.១ តួនាទីរបស់មេធាវី ក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ ............ ៣៧
ក.តួនាទីផ្សះផ្សាដោយមេធាវី ............ ៣៧
ខ.តួនាទីធ្វើសេចក្ដីថ្លែងការណ៍ដោយមេធាវី ............ ៣៨
គ.ការដាក់មធ្យោបាយ ត ទល់ ឬការពារខ្លួនជាថ្មី ............ ៣៨
២.២.២. តួនាទីនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ............ ៣៩
ក.តួនាទីរបស់មេធាវី ក្នុងការធ្វើសេចក្ដីសន្និដ្ឋាន ............ ៣៩
២.៣. តួនាទីរបស់មេធាវី ក្រោយបញ្ចប់ពេលជំនុំជម្រះ ............ ៣៩

២.៣.១. តួនាទីក្នុងការពន្យល់ពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យដល់កូនក្តី.................. ៣៩
ក. បណ្តឹងឧបាស្រ័យ ........................................................................... ៣៩
ក.១. បណ្តឹងឧទ្ធរណ៍ ........................................................................... ៤០
ក.២. បណ្តឹងសាទុក្ខ ........................................................................... ៤០
ក.៣. បណ្តឹងតវ៉ា ........................................................................... ៤១
ក.៤. បណ្តឹងជំទាស់........................................................................... ៤១
ក.៥. បណ្តឹងតវ៉ា........................................................................... ៤១
សេចក្តីសន្និដ្ឋាន........................................................................... ៤៣
អនុសាសន៍........................................................................... ៤៤
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈដែលមានភាពចាំបាច់សម្រាប់ដោះស្រាយបញ្ហាសម្រាប់ប្រជាពលរដ្ឋកម្ពុជា ប៉ុន្តែក្រោយពីប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលមកឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប្រជាជនកម្ពុជាទាំងអស់បាត់បង់នូវសិទ្ធសម្រាប់ការពារខ្លួនតាមផ្លូវតុលាការ។ ការដាក់ទណ្ឌកម្មយ៉ាងឃោឃៅលើរូបរាងកាយ ការឃុំឃាំងខ្លួន និងការប្រហារជីវិតត្រូវបានយកមកអនុវត្តតាមការសម្រេចរបស់មេអង្គការ ដោយមិនឆ្លងកាត់នីតិវិធីតុលាការឡើយ។ រីឯបុគ្គលដែលមានចំណេះជំនាញផ្នែកច្បាប់ភាគច្រើនត្រូវបានបាត់បង់ជីវិតដោយសារការសម្លាប់រង្គាល និងការជម្លាសប្រជាជនចេញពីក្នុងប្រទេសកម្ពុជា រួមទាំងត្រូវបានបំភ្លេចបំផ្លាញឯកសារច្បាប់សំខាន់ផ្សេងៗដោយសោកនាដកម្មពេលនោះផងដែរ។ ប៉ុន្តែក្រោយពីប្រទេសកម្ពុជាត្រូវបានរំដោះពីរបបកម្ពុជាប្រជាធិបតេយ្យ និងបានកសាងប្រទេសឡើងវិញ ហើយរដ្ឋធម្មនុញ្ញលើកទី៤ ដែលអនុម័តដោយរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ១៩៨១ និងត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៨១ ទើបមានបញ្ញត្តិអំពីសិទ្ធិក្នុងការទទួលបានការការពារផ្លូវតុលាការឡើងវិញ។ ចំណែកឯ ការចាត់តាំងមេធាវីក៏បានចាប់ផ្តើម បន្ទាប់ពីមានការបង្កើតតុលាការខេត្ត-ក្រុងបដិវត្តប្រជាជនក្នុងឆ្នាំ ១៩៧៩ តុលាការកំពូលក្នុងឆ្នាំ ១៩៨៥ និងសាលាឧទ្ធរណ៍ក្នុងឆ្នាំ ១៩៩២។ នៅក្នុងឆ្នាំ១៩៩២ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដែលមានការជួយជ្រោមជ្រែងពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជាបានអនុម័តបទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ព្រហ្មទណ្ឌ និងច្បាប់នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ហៅកាត់ថា **"ច្បាប់ព្រហ្មទណ្ឌអន្តរកាល"**។ ច្បាប់ព្រហ្មទណ្ឌអន្តរកាលនេះទៀតសោតបានផ្តល់ លទ្ធភាពដល់ការបង្កើតគណៈមេធាវី និងសិទ្ធិរបស់ជនជាប់ចោទក្នុងការមានមេធាវីជាតំណាង និងការការពារសិទ្ធិនៅក្នុងដំណើរការនីតិវិធីតុលាការ។

លើសពីនេះទៀត សិទ្ធិទទួលបានការតំណាងពីមេធាវីដើម្បីការពារសិទ្ធិជនជាប់ចោទនៅក្នុងដំណើរការជំនុំជម្រះក្តី មិនត្រឹមតែនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ ១៩៩២ ប៉ុណ្ណោះទេ សម្រាប់ឯរដ្ឋធម្មនុញ្ញលើកទី៥ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ក៏បានទទួលស្គាល់ពីការការពារសិទ្ធិដល់ជនជាប់ចោទផងដែរ។ រដ្ឋធម្មនុញ្ញបែបប្រជាធិបតេយ្យរបស់កម្ពុជាបានទទួលស្គាល់នូវការការពារសិទ្ធិជាមូលដ្ឋានរបស់មនុស្ស ដូចដែលបានប្រកាសនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងនៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សនៅក្នុងឆ្នាំ ១៩៤៨ និងក្នុងអនុសញ្ញា កតិកាសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដទៃទៀតដែលមានជាធរមាន។

ដូចនេះហើយ ទើបផ្តល់លទ្ធភាពដល់ក្រុមនីតិប្បញ្ញត្តិដាក់បញ្ចូលនូវសិទ្ធិរបស់មេធាវីទៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ដើម្បីជាប្រយោជន៍ដល់មេធាវីក្នុងការប្រើសិទ្ធិសម្រាប់ដំណើរនីតិវិធីតុលាការ។

ជាការពិតណាស់ វត្តមានរបស់មេធាវីដើរតួនាទីយ៉ាងសំខាន់ទាំងក្នុងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌដើម្បីការពារសិទ្ធិរបស់ដើមចោទ ចុងចម្លើយ និងជនល្មើសជាអាទិ៍។ ដោយឡែក ក្រុមយើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះប្រធានបទស្តីពី **សិទ្ធិ និងតួនាទីរបស់មេធាវីក្នុងសាលាជម្រះក្តីជាន់ទាប** ព្រោះតែការអនុវត្តភារកិច្ចរបស់មេធាវីគឺពិតជាចាំបាច់នូវសិទ្ធិដែលផ្តល់ដោយស្របច្បាប់ដើម្បីការពារពីការជ្រៀតជ្រែកមុខងារ និងការប្រើប្រាស់សិទ្ធិដោយបំពានចំពោះមេធាវីផងដែរ។

ហើយក្នុងឱកាសនេះ ក្រុមយើងខ្ញុំមានលទ្ធភាពទទួលបានការបកស្រាយលម្អិតថា **តើធ្វើដូចម្តេចដើម្បីទទួលបានសិទ្ធិក្លាយជាមេធាវីនៅកម្ពុជា? តើការវិវឌ្ឍវិជ្ជាជីវៈមេធាវីនៅកម្ពុជាដល់កម្រិតណា? តើមេធាវីមានគណនេយ្យភាពយ៉ាងដូចម្តេច? តើមេធាវីបំពេញភារកិច្ចអ្វីខ្លះក្នុងរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណីចាប់តាំងពីមុនពេលជំនុំជម្រះ ក្នុងអំឡុងពេលជំនុំជម្រះ និងក្រោយបញ្ចប់ពេលជំនុំជម្រះ? តើច្បាប់ណាខ្លះដែលផ្តល់សិទ្ធិដល់មេធាវីក្នុងការអនុវត្តភារកិច្ច?**

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃមេធាវីនៅកម្ពុជា

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃមេធាវីនៅកម្ពុជា

## ១.ប្រវត្តិសាស្ត្រនៃការវិវត្តវិជ្ជាជីវៈមេធាវីនៅកម្ពុជា

ប្រព័ន្ធមេធាវីនៅកម្ពុជា មានប្រវត្តិមិនជាយូឆ្នាំដូចប្រទេសអភិវឌ្ឍន៍នោះទេ ដោយសារប្រទេសកម្ពុជាជាប្រទេសរាជានិយមមានទម្លាប់ដោះស្រាយវិវាទដោយព្រះមហាក្សត្រ មេភូមិ ព្រះសង្ឃ ឬអ្នកជិតខាង ជាដើម។ ការគ្រប់គ្រងរដ្ឋបែបទំនើប ទើបតែត្រូវបាននាំចូលក្នុងសម័យអាណានិគមបារាំងអំឡុងសតវត្សទី១៩ តែប៉ុណ្ណោះ នៅក្នុងឆ្នាំ ១៩៣២ មានការណែនាំឱ្យស្គាល់ជាផ្លូវការនូវវិជ្ជាជីវៈមេធាវីនៅក្នុងប្រទេសកម្ពុជាដោយព្រះរាជប្រកាសលេខ៣២ ចុះថ្ងៃទី១៥ មីនាឆ្នាំ ១៩៣២ ដែលក្រោយមកត្រូវបានធ្វើវិសោធនកម្មដោយព្រះរាជក្រមលេខ ៦៤៨ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៥១។ ព្រះរាជប្រកាសលេខ៣២បានណែនាំឱ្យស្គាល់នូវ **ស្នាក្តី** និងអ្នកដែលអនុវត្តវិជ្ជាជីវៈនេះត្រូវបានហៅថា **អ្នកថណាយក្តី** ។

នៅក្នុងឆ្នាំ ១៩៤៧ កម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញទី១ របស់ខ្លួនដែលទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ហើយការ ចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនអាចធ្វើទៅបានលុះត្រាតែអនុវត្តត្រឹមត្រូវតាមបទបញ្ញត្តិច្បាប់។ ការចាប់ខ្លួនត្រូវផ្អែកទៅតាមនីតិវិធីដែលកំណត់នៅក្នុងច្បាប់ហើយមានមូលដ្ឋានជាក់លាក់ និងសម្រេចដោយតុលាការ។ នៅឆ្នាំ ១៩៧២ រដ្ឋធម្មនុញ្ញទី២ បានចែងយ៉ាងច្បាស់ពីសិទ្ធិរបស់ជនគ្រប់រូបក្នុងការការពារខ្លួនតាមផ្លូវតុលាការ។[1] ជាអកុសលសិទ្ធិទាំងនេះត្រូវបានលុបបំបាត់នៅក្នុងអំឡុងពេលប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប្រជាជនទាំងអស់គ្មានសិទ្ធិសេរីភាព និងគ្មានសិទ្ធិអ្វីទាំងអស់ ព្រមទាំងសិទ្ធិការការពារខ្លួនតាមផ្លូវតុលាការទៀតផង។ ការកាត់ទោសនានា ដូចជាការដាក់ទណ្ឌកម្ម ឬការកាត់ទោសប្រហារជីវិតត្រូវបានយកមកអនុវត្តតាមការសម្រេចរបស់មេអង្គការ ដោយគ្មានការជំនុំជម្រះតាមនីតិវិធីតុលាការឡើយ។[2] ដោយគ្មានការជំនុំជម្រះតាមនីតិវិធីតុលាការឡើយ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិតេយ្យបានដួលរលំ សិទ្ធិក្នុងការទទួលបានការការពារតាមផ្លូវច្បាប់ក៏បានកើតឡើងជាថ្មីម្តងទៀតដោយរដ្ឋធម្មនុញ្ញទី៤ ឆ្នាំ ១៩៨១ អនុម័តដោយរដ្ឋសភាប្រជាជនកម្ពុជានៃសាធារណប្រជាមានិតកម្ពុជា។ ទោះបីជាយ៉ាងនេះក្តីក៏ការអនុវត្តសិទ្ធិទាំងនេះស្ទើតែមិនអាចធ្វើទៅបានដោយសារតែមេធាវីជាច្រើនរូបត្រូវបានគេសម្លាប់ ហើយអ្នកចេះដឹងផ្នែកវិស័យច្បាប់ក៏មាននៅសល់តិចតួចតែបំផុត ដែលធ្វើឲ្យវិស័យនេះត្រូវបានធ្លាក់ចុះយ៉ាងដុនដាប។ ហើយការចាប់ផ្តើមជាថ្មីនៃវិជ្ជាជីវៈមេធាវី ធ្វើឡើងបន្ទាប់ពីមានការបង្កើតតុលាការ

[1] មាត្រា ៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ១៩៧២

[2] អង្គការ សំដៅដល់អង្គភាពរដ្ឋបាល នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

ខេត្ត ក្រុងបដិវត្តប្រជាជនក្នុងឆ្នាំ១៩៧៩។ ប៉ុន្តែបើមើលតាមច្បាប់ដែលត្រូវបានប្រើប្រាស់ក្នុងសម័យកាលអន្តរកាលនេះ វិជ្ជាជីវៈមេធាវីត្រូវបានប្រើប្រាស់ឡើងវិញក្នុងឆ្នាំ ១៩៩២ ។ **ក្នុងរយៈពេលអន្តរកាល ជនដែលអាចធ្វើជាមេធាវីបាន គឺជនទាំងឡាយណាដែលយ៉ាងហោចណាស់ មានសញ្ញាបត្រស្មើនឹងបរិញ្ញាបត្រនីតិសាស្ត្រ ឬមានបទពិសោធន៍ ៥ឆ្នាំ ក្នុងវិស័យច្បាប់ ឬវិស័យតុលាការ ប្រកបដោយកម្រិតខ្ពស់ទទួលខុសត្រូវក្នុងកិច្ចការ បាន។ ដោយចំនួនមេធាវីមានតិចតួចពេកនៅប្រទេសកម្ពុជា ក្នុងរយៈពេលអន្តរកាលនេះ ប្រជាជនកម្ពុជាគ្រប់រូបដែលមានសញ្ញាបត្រមធ្យមសិក្សា អាចតំណាងអោយជនជាប់ចោទនៅចំពោះមុខតុលាការបាន។**[3] រហូតដល់ឆ្នាំ ១៩៩៥ តាមរយៈការបង្កើតគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា វិជ្ជាជីវៈមេធាវីនៅកម្ពុជាត្រូវបានរៀបចំឡើងវិញ ដោយមានការចុះបញ្ជីនៅក្នុងបញ្ជីមេធាវីដើម្បីប្រកបវិជ្ជាជីវៈនេះ និងចាប់ផ្តើមមានការជ្រើសរើសបេក្ខជនប្រឡងចូលរៀនក្នុងវគ្គបណ្តុះបណ្តាលមេធាវី។ យោងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ជនដែលអាចប្រកបវិជ្ជាជីវៈជាមេធាវីបានត្រូវមាន វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីចេញដោយមជ្ឈមណ្ឌលបណ្តុះ បណ្តាលវិជ្ជាជីវៈមេធាវី។ ប៉ុន្តែដោយសារតែនៅឆ្នាំ ១៩៩៥ មជ្ឈមណ្ឌលនេះគឺពុំទាន់បានបង្កើតនៅឡើយ គណៈមេធាវីបានបង្កើតវគ្គបណ្តុះបណ្តាលត្រឹមរយៈពេល ៨ខែ ដើម្បីបំពេញតម្រូវការមេធាវីក្នុងសង្គម។ រីឯអ្នកដែលអាចប្រឡងចូលរៀនវគ្គនេះបាន គឺអ្នកដែលមានបទពិសោធន៍ការពារក្តីរយៈពេលយ៉ាងតិច ២ឆ្នាំ និងមន្ត្រីរាជការដែលបានបម្រើការងាររដ្ឋយ៉ាងតិច ២ឆ្នាំ។ លើសពីនេះទៅទៀតអ្នកមានបរិញ្ញាបត្រច្បាប់ ឬសញ្ញាបត្រសមមូលដែលបានបំពេញការងារនៅក្នុងវិស័យច្បាប់ ឬតុលាការយ៉ាងតិច ២ឆ្នាំ ឬអ្នកមានសញ្ញាបត្របណ្ឌិតច្បាប់ និងចៅក្រម ឬអតីតចៅក្រមដែលបានបំរើការងារយ៉ាងតិច ២ឆ្នាំ អាចដាក់ពាក្យសុំចុះបញ្ជីជាមេធាវី ដោយពុំចាំបាច់ឆ្លងកាត់ការប្រឡង ការបណ្តុះបណ្តាល ឬកម្មសិក្សាឡើយ។ ការចុះបញ្ជីមេធាវីដូចខាងលើត្រូវបានអនុវត្តរយៈពេល ២ឆ្នាំ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៧។ ចំណែកឯនៅត្រឹមឆ្នាំ ២០០១ មានអនុក្រឹត្យដែលស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែមជ្ឈមណ្ឌលជាក់ស្តែងពុំទាន់បានបង្កើតនៅក្នុងឆ្នាំនោះនៅឡើយទេ។ រហូតដល់ឆ្នាំ ២០០២ ទើបចាប់ផ្តើមមានការប្រឡងប្រជែងជ្រើសរើសសិស្សមេធាវីអោយចូលរៀននៅមជ្ឈមណ្ឌលនេះ។ ពុំមានឯកសារណាសរសេរពីចំនួនមេធាវីដែលបានចុះបញ្ជីនៅមុនពេលមានមជ្ឈមណ្ឌមេធាវីនោះទេ។ ប៉ុន្តែ យោងតាមទិន្នន័យចុះបញ្ជីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គិតត្រឹមខែមិថុនា ឆ្នាំ២០២១ ដែលក្នុងនោះមាន៖[4]

- មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈមានចំនួន ១៨៤៦ រូប

---

[3] មាត្រា ៧ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនិតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល

[4] អំណះអំណាង https://www.bakc.org.kh/index.php/km/2017-07-24-08-31-04

ចូលមើលនៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២១

- មេធាវីកំពុងធ្វើកម្មសិក្សាមានចំនួន ៣៣០ រូប
- មេធាវីសុំមិនប្រកបវិជ្ជាជីវៈមានចំនួន ១២៤ រូប
- មេធាវីព្យួរកម្មសិក្សាមាន គ្មាន (០០រូប )
- មេធាវីព្យួររបាយការណ៍កម្មសិក្សាមានចំនួន ០៣ រូប
- មេធាវីសុំនៅក្រៅបញ្ជីមានចំនួន ២៥ រូប
- មេធាវីហាមឃាត់ប្រកបវិជ្ជាជីវៈមានចំនួន ០២ រូប
- មេធាវីផ្អាកពីមុខងារបណ្តោះអាសន្នមានចំនួន ០១ រូប
- មេធាវីលុបឈ្មោះចេញពីគណៈមេធាវីមានចំនួន ២២ រូប។

## ២.លិខិតបទដ្ឋានទាក់ទងនឹងមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

### ២.១. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានកំណត់ថាវិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលបានចូលរួមបម្រើវិស័យយុត្តិធម៌។[5] មេធាវីជាអ្នកផ្តល់យោបល់និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យច្បាប់ ហើយមេធាវីក៏អាចជាអ្នកតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងនៅគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿង រដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ចជាដើម។[6] ចំពោះរឿងព្រហ្មទណ្ឌ មេធាវីជួយការពារជនជាប់ចោទ ហើយមិនអាចតំណាងជនជាប់ចោទបានឡើយ លើកលែងតែមានបទបញ្ញត្តិពិសេសនៃច្បាប់។ ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាម គតិយុត្តបានឡើយលើកលែងតែការពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាមនោះជាការងារបន្ទាប់បន្សំនៃមុខរបររបស់ខ្លួន ឬជាមុខងារដែលច្បាប់បានអនុញ្ញាត។ មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីប្រទេសក្រៅ ឬដែលប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឲ្យប្រកបវិជ្ជាជីវៈមេធាវី មានសិទ្ធិចូលរួមប្រកបវិជ្ជាជីវៈជាមួយមេធាវីខ្មែរហើយអមមេធាវីខ្មែរនៅចំពោះមុខតុលាការ ឬស្ថាប័នដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា។[7] មេធាវីនោះពុំអាចតំណាងកូនក្តីបានឡើយ។ មេធាវីបរទេសអាចប្រកបវិជ្ជាជីវៈនៅផែនដីព្រះរាជាណាចក្រកម្ពុជាបានលុះត្រាតែមានការយល់ព្រមពីក្រុមប្រឹក្សាគណៈមេធាវីខ្មែរ ផ្អែកលើលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់មេធាវីនោះ

[5] មាត្រា១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[6] មាត្រា២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[7] មាត្រា៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

ហើយលុះត្រាតែប្រទេសដើមរបស់មេធាវីបរទេសនោះ ផ្តល់លទ្ធភាពដូចគ្នាដល់មេធាវីខ្មែរផងដែរ។[8] ការយល់ព្រមអាចដកហូតវិញបាន បើមានការប្រព្រឹត្តិខុសក្នុងការ ប្រកបវិជ្ជាជីវៈលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីសម្រេចមិនអនុញ្ញាត ឬដកហូតការអនុញ្ញាតរបស់ក្រុមប្រឹក្សាគណៈមេធាវី មិនឲ្យប្រកបវិជ្ជាជីវៈ ត្រូវជូនដំណឹងក្នុងរយៈពេល ១៥ថ្ងៃ ពីអគ្គព្រះរាជអាជ្ញាអបសាលាឧទ្ធរណ៍ និងទៅសាមីខ្លួន។ សេចក្តីសម្រេចនេះអាចប្តឹងទៅសាលាឧទ្ធរណ៍បានក្នុងរយៈពេល ២ខែ ក្រោយពីទទួលបានដំណឹង។

ហេតុនេះហើយបានជាមានច្បាប់មួយបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៥ ព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ដែលស្តីពី **ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី** បង្កើតឡើងដើម្បីបណ្តុះបណ្តាលឲ្យមេធាវីគ្រប់រូបនូវ បទបញ្ជាផ្ទៃក្នុង បច្ចេកទេសការពារកូនក្តី និងក្រមសីលធម៌វិជ្ជាជីវៈមេធាវី។

### ២.១.១. នីតិវិធីការចូលប្រកបវិជ្ជាជីវៈ

#### ក. តាមរយៈការប្រឡង

ជនដែលអាចចូលប្រកបវិជ្ជាជីវៈមេធាវី គឺត្រូវមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីដែលវិញ្ញាបនបត្រនេះត្រូវចេញដោយមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។[9] ហើយដើម្បីទទួលបានវិញ្ញាបនបត្រនេះគឺត្រូវឆ្លងកាត់ការប្រឡងចូលមជ្ឈមណ្ឌលនិងទទួលការការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

#### ក.១. លក្ខខណ្ឌ

ដើម្បីប្រឡងចូលជាសិស្សមេធាវី និងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី បេក្ខជនត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជា[10]៖

- បេក្ខជនទាំង ពីរ ភេទត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានបរិញ្ញាបត្រច្បាប់ ឬ សញ្ញាបត្រច្បាប់ ដែលបានប្រកាសថាមានតម្លៃសមមូល
- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬផ្តន្ទាទោសជារដ្ឋបាល ដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើថ្មុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ។ ហើយមិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។
- ត្រូវមានសីលធម៌ និងកាយសម្បទាគ្រប់គ្រាន់។

[8] មាត្រា៦ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[9] មាត្រា ៣១ វាក្យខ័ណ្ឌទី៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[10] មាត្រា ៧ នៃអនុក្រឹតស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឆ្នាំ២០០៨

### ក.២. ការប្រឡង

ការកំណត់ចំនួនសិស្សមេធាវី និងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សមេធាវី កម្មវិធីបណ្តុះបណ្តាលគ្រូបណ្តុះបណ្តាល និងការប្រឡងយកវិញ្ញាបនប័ត្រសម្បទាវិជ្ជាជីវៈមេធាវី ត្រូវពិនិត្យនិងសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។[11] ការប្រឡងមានវិញ្ញាសារពីរប្រភេទ គឺវិញ្ញាសារសរសេរ **(ប្រឡងលើទី១)** និងវិញ្ញាសារផ្ទាល់មាត់ **(ចំពោះបេក្ខជនដែលបានប្រឡងជាប់លើវិញ្ញាសារសរសេររួច)**។[12]

### ក.៣. ការចុះកម្មសិក្សា

នៅពេលដែលបានបញ្ចប់វគ្គសិក្សានៅមជ្ឈមណ្ឌលដោយជោគជ័យរួច ក្រុមប្រឹក្សាគណៈមេធាវីនឹងធ្វើការពិនិត្យមើលលើរាល់លក្ខខណ្ឌដែលបេក្ខជនត្រូវបំពេញ និងធ្វើការសម្រេចចំពោះការអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈ ។[13] បន្ទាប់មក មេធាវីដែលត្រូវបានទទួលឱ្យប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះមុខប្រធានសាលាឧទ្ធរណ៍ ដែលមានវត្តមានប្រធានគណៈមេធាវីផង។ បន្ទាប់មកទៀត មេធាវីដែលទើបតែបានចុះឈ្មោះនោះ ត្រូវធ្វើកម្មសិក្សារយៈពេល ១ឆ្នាំ ដែលក្នុងអំឡុងពេលមួយឆ្នាំនោះ មេធាវីនោះត្រូវទទួលការបំពាក់បំប៉នបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី និងត្រូវកំណត់ឱ្យចូលរួមបំពើការងារនៅក្នុងការិយាល័យមេធាវីណាមួយ ហើយនៅក្រោមការពិនិត្យរបស់មេធាវីម្នាក់ដែលក្រុមប្រឹក្សាគណៈមេធាវីចាត់តាំងឱ្យទទួលខុសត្រូវលើកម្មសិក្សានោះ ។[14]

## ខ. តាមការស្នើសុំ

### ខ.១. លក្ខខណ្ឌ

ការស្នើសុំប្រកបវិជ្ជាជីវៈមេធាវីគឺមិនចាំបាច់មានវិញ្ញាបនបត្រវិជ្ជាជីវៈមេធាវី និងបរិញ្ញាបត្រច្បាប់ទេ តែត្រូវបំពេញទៅតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ករណីគ្មានវិញ្ញាបនបត្រវិជ្ជាជីវៈមេធាវី និងបរិញ្ញាប័ត្រច្បាប់
  - ចៅក្រមដែលបានបំពើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ឆ្នាំ
  - អតីតចៅក្រម ដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់ហើយ ដែលបានបម្រើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ឆ្នាំ។[15]
- ករណីគ្មានវិញ្ញាបនបត្រខាងវិជ្ជាជីវៈមេធាវី តែត្រូវមានបរិញ្ញាប័ត្រច្បាប់

[11] មាត្រា ៦ នៃអនុក្រឹតស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឆ្នាំ២០០៨

[12] មាត្រា ២៤ នៃសេចក្តីសម្រេចស្តីពី នីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ឆ្នាំ២០២១

[13] មាត្រា ៣៧ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[14] មាត្រា ៣៥ និងមាត្រា ៣៦ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[15] មាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

- អ្នកមានបរិញ្ញាបត្រច្បាប់ ហើយបានបំពេីការងារក្នុងវិស័យច្បាប់ឬតុលាការលើសពី ២ឆ្នាំ
- មេធាវីដែលមានសញ្ជាតិដើមខ្មែរដែលចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ
- អ្នកមានសញ្ញាបត្របណ្ឌិតច្បាប់។[16]

## ខ.២. ការដាក់ពាក្យសុំ

បុគ្គលណាដែលមានបំណងចង់ស្នើសុំប្រកបវិជ្ជាជីវៈមេធាវី ហើយដែលបានបំពេញតាមលក្ខខណ្ឌនៃមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី គឺគេត្រូវទៅទាក់ទងខាងការិយាល័យរដ្ឋបាលនៃគណៈមេធាវីនៅវាល់ម៉ោងធ្វើការ។ ហើយចំពោះការដាក់ពាក់សុំនេះគឺតម្រូវឲ្យបង់ថ្លៃលើពាក្យសុំនេះ ដែលការកំណត់ទម្រង់ពាក្យសុំនិងតម្លៃនៃពាក្យនេះគឺកំណត់ដោយគណៈមេធាវី។[17] នៅក្រោយពេលដែលបំពេញពាក្យសុំរួចរាល់គេត្រូវយកពាក្យសុំនោះទៅដាក់នៅការិយាល័យរដ្ឋបាលគណៈមេធាវី ដោយភ្ជាប់ជាមួយឯកសារមួយចំនួនរួមមាន[18] ៖

- ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២
- ប្រវត្តិរូបសង្ខេបសាមីខ្លួន
- លិខិតថ្កោលទោសដែលនៅមានសុពលភាព
- ឯកសារតម្រូវផ្សេងៗទៀត ដែលកំណត់ដោយគណៈមេធាវី។

## ខ.៣. ការដាក់ពាក្យធ្វើកម្មសិក្សា

បន្ទាប់ពីគណៈមេធាវីបានពិនិត្យ និង បញ្ជូនឯកសារពាក្យសុំនោះទៅក្រុមអធិការកិច្ច ក្រុមអធិការកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងរយៈពេលយូរបំផុត ៣០ថ្ងៃ ហើយត្រូវធ្វើរបាយការណ៍អធិការកិច្ច និងបញ្ជូនរបាយការណ៍ នោះទៅកាន់ប្រធាននាយកដ្ឋានអធិការកិច្ចដើម្បីត្រួតពិនិត្យ និងវាយតម្លៃ មុននឹងត្រូវបញ្ជូនទៅប្រធានគណៈមេធាវី។ បើរបាយការណ៍នោះត្រឹមត្រូវ និងមិនមានខ្វះចន្លោះចំណុចអ្វីទេនោះ ប្រធានគណៈមេធាវីត្រូវកំណត់ពេលដើម្បីធ្វើការសំភាសន៍បេក្ខជនផ្ទាល់ក្នុង រយៈពេល ៣០ថ្ងៃ។[19] នៅពេលដែលការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីបានបោះឆ្នោតសម្រេចយល់ព្រមចំពោះសំណើនោះដោយមានសម្លេងគាំទ្រភាគច្រើន គឺមានន័យថាបេក្ខជននោះគឺទទួលបានការអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈមេធាវីហើយ។ បន្ទាប់ពីបេក្ខជនធ្វើសច្ចាប្រណិធានចំពោះមុខប្រធានសាលាឧទ្ធរណ៍រួច បេក្ខជននោះត្រូវដាក់ពាក្យសុំធ្វើកម្មសិក្សានិងចុះធ្វើកម្មសិក្សា

[16] មាត្រា ៣២ វាក្យខណ្ឌ២ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[17] ប្រការ ៦ នៃសេចក្តីសម្រេចពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ ឆ្នាំ២០១៧

[18] ប្រការ ៧ នៃសេចក្តីសម្រេចពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ ឆ្នាំ២០១៧

[19] ប្រការ ១៤ នៃសេចក្តីសម្រេចពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ ឆ្នាំ២០១៧

រយៈពេល ១២ខែ និងធ្វើរបាយការណ៍បញ្ចប់ការសិក្សាដាក់ឲ្យគណៈមេធាវីពិនិត្យ និងសម្រេចពីការអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យក្លាយជាមេធាវីពេញសិទ្ធិ។

### ២.២. ក្រមសីលធម៌វិជ្ជាជីវៈមេធាវី (ការប្រកបវិជ្ជាជីវៈ)

ក្នុងការប្រកបវិជ្ជាជីវៈមេធាវី មេធាវីត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌មេធាវី ជាពិសេសគោរពតាមគោលការណ៍នីមួយៗតាមការអនុញ្ញាតរបស់ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

#### ២.២.១. ឯករាជ្យភាព និងសេរីភាព នៃវិជ្ជាជីវៈមេធាវី

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌ និងប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវីប៉ុណ្ណោះ។[20] វិជ្ជាជីវៈមេធាវីស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គណៈមេធាវីដែលជាស្ថាប័នឯករាជ្យពីគណៈបក្សនយោបាយ អង្គការសាសនាឬអង្គការនានាផ្សេងទៀត។[21] ឯករាជ្យភាពនៃវិជ្ជាជីវៈមេធាវីមានន័យថា នៅពេលអនុវត្តវិជ្ជាជីវៈរបស់ខ្លួនមេធាវីម្នាក់ៗមិនស្ថិតនៅក្រោមបញ្ជា ឬការណែនាំពីបុគ្គលណាម្នាក់ ឬពីស្ថាប័នណាមួយឡើយ។ នៅក្នុងការផ្តល់សេវាកម្មច្បាប់ មេធាវីគ្រប់រូបត្រូវធ្វើឡើងដោយគោរពតាមច្បាប់ បទប្បញ្ញត្តិជាធរមាន និងវិធានវិជ្ជាជីវៈ ហើយបំពេញការងារតាមបច្ចេកទេសតាមជំនាញរបស់ខ្លួន ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជនដោយមិនចំណុះនិងស្ថិតនៅក្រោមការជ្រៀតជ្រែករបស់ស្ថាប័ន ឬបុគ្គលណាមួយឡើយ។ មេធាវីអនុវត្តវិជ្ជាជីវៈដោយផ្អែកទៅលើ ជំនាញវិជ្ជាជីវៈរៀងៗខ្លួនយោងទៅតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងក្រមសីលធម៌មេធាវីដោយមិនអនុវត្តវិជ្ជាជីវៈទៅតាមការណែនាំ ឬឥទ្ធិពលណាមួយឡើយ។ រីឯសេរីភាពនៃវិជ្ជាជីវៈមេធាវី គឺមានន័យថាមេធាវីមានសេរីភាពពេញលេញក្នុងការជ្រើសរើស ទីកន្លែងប្រកបវិជ្ជាជីវៈ សេរីភាពទទួល ឬមិនទទួលការផ្តល់សេវាកម្មច្បាប់ជូនអតិថិជន សេរីភាពក្នុងការកំណត់កម្រៃសេវា និងសេរីភាពក្នុងការជ្រើសរើសមធ្យោបាយបំពេញការងារជាដើម។ កម្រៃសេវារបស់មេធាវីគឺអាស្រ័យតាមការព្រមព្រៀងរវាងមេធាវី និងអតិថិជន ពោលគឺច្បាប់ ឬបទដ្ឋានគតិយុត្តពុំបានកំណត់ពីអត្រានៃកម្រៃសេវារបស់មេធាវីទេ។ មេធាវីមានតួនាទីការពារសិទ្ធិ សេរីភាពរបស់បុគ្គល និងជួយពង្រឹងយុត្តិធម៌សង្គម។ មេធាវីជាជំនួយការយុត្តិធម៌របស់សង្គម។ នៅក្នុងករណីមេធាវីប្រព្រឹត្តបំពាននឹងវិធានវិជ្ជាជីវៈ មេធាវីនឹងត្រូវទទួលទណ្ឌកម្មពីក្រុមប្រឹក្សាគណៈមេធាវី ។[22]

[20] មាត្រា ១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[21] មាត្រា ១៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[22] មាត្រា ៥៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

### ២.២.២. តម្លៃសីលធម៌នៃវិជ្ជាជីវៈមេធាវី

#### ក. សញ្ញាណទូទៅ

នៅគ្រប់កាលៈទេសៈមេធាវីត្រូវគោរពពាក្យសម្បថ និងត្រូវគោរពគោលការណ៍នៃសម្បជញ្ញៈមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈ។ មេធាវីត្រូវអនុវត្តវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយសេចក្តីថ្លៃថ្នូរនិងប្រកបដោយសតិសម្បជញ្ញៈ សេចក្តីទៀងត្រង់ មនុស្សធម៌ ស្មារតីឯករាជ្យដោយគោរពតាមរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា។ មេធាវីមិនត្រូវចូលរួមសកម្មភាពណា ដែលមានលក្ខណៈផ្ទុយវិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួនឡើយ។ មេធាវីត្រូវគោរពនិងប្រតិបត្តិនូវគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់។[23] មេធាវីមានបេសកកម្មចូលរួមក្នុងការរៀបចំនីតិរដ្ឋជួយពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស។[24]

#### ខ. ការទទួលរឿងក្តី

មេធាវីមានសិទ្ធិទទួល ឬមិនទទួលអតិថិជន លើកលែងតែត្រូវចាត់តាំងដោយប្រធានគណៈមេធាវី ។ មេធាវីអាចទទួលរឿងក្តីតាមរយៈកូនក្តីដោយផ្ទាល់ ឬតតិយជនដូចជាប្រធានគណៈមេធាវីជាដើម ។ ប្រសិនបើយល់ព្រមទទួលយកបេសកកម្មនោះ មេធាវីត្រូវបំពេញបេសកកម្មនោះដោយយកចិត្តទុកដាក់រហូតដល់ចប់បេសកកម្ម លើកលែងតែអតិថិជនឈប់ពឹងពាក់។ មេធាវីត្រូវពន្យល់ប្រាប់អតិថិជនរបស់ខ្លួនអំពីលក្ខខណ្ឌនៃរឿងក្តី ហើយជម្រើសនៃវិធីដោះស្រាយ កម្រៃសេវាមេធាវី និងកម្រៃផ្សេងៗទៀត ដោយផ្អែកលើព័ត៌មានដែលទទួលបានពីអតិថិជន។ នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនមេធាវី ត្រូវស្ថិតនៅជាម្ចាស់មធ្យោបាយការពារ ហើយមេធាវីមិនត្រូវផ្តល់ការធានាចំពោះអតិថិជនទាក់ទងនឹងលទ្ធផលវិជ្ជមាននៃរឿងក្តីឡើយ។[25] មេធាវីទទួលការពារ និងតំណាងរឿងក្តីទៅតាមការពឹងពាក់ពីអតិថិជន។ នៅក្នុងការងារការពារក្តីជូនជនក្រីក្រ មេធាវីទទួលការពារក្តីតាមការចាត់តាំងរបស់ប្រធានគណៈមេធាវី។ មេធាវីទាំងអស់មានកាតព្វកិច្ចជួយការពារក្តីជូនជនក្រីក្រតាមការចាត់តាំងរបស់ប្រធានគណៈមេធាវី ហើយត្រូវយកចិត្តទុកដាក់ការពារក្តីឱ្យដូចជាការការពារក្តីឱ្យអតិថិជនដែលមកពឹងពាក់ខ្លួនដែរ។[26]

#### គ. ការប្រុងប្រយ័ត្ន

ករណីដែលមេធាវីព្រមទទួលរឿងក្តីរបស់អតិថិជន មេធាវីត្រូវគិតពីផលប្រយោជន៍របស់អតិថិជនឱ្យដូចជាផលប្រយោជន៍របស់ខ្លួនដែរ។ ដូចនេះ មេធាវីត្រូវប្រើប្រាស់នូវសមត្ថភាពនិងជំនាញវិជ្ជាជីវៈដែលខ្លួនមាន

---

[23] មាត្រា ៣៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងមាត្រា ៣ និងមាត្រា ៦ នៃក្រមសីលធម៌មេធាវី ឆ្នាំ ២០១២

[24] មាត្រា ៤ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[25] មាត្រា ២២ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[26] មាត្រា ២៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

ទាំងអស់ដើម្បីបំពេញកិច្ចការដែលអតិថិជនបានពឹងពាក់ប្រកបដោយការប្រុងប្រយ័ត្ន។ ក្នុងករណីដែលមានការធ្វេសប្រហែស អតិថិជនអាចប្តឹងមេធាវីចំពោះការខូចខាតបាន។ **ឧទាហរណ៍៖** អតិថិជនបានពឹងពាក់មេធាវីឱ្យរៀបចំធ្វើបណ្តឹងឧទ្ធរណ៍នឹងសាលក្រមរបស់សាលាដំបូងដែលខ្លួនមិនសុខចិត្ត តែមេធាវីធ្វើការធ្វេសប្រហែសដោយខកខានមិនបានរៀបចំប្តឹងឧទ្ធរណ៍ នឹងសាលក្រមរបស់សាលាដំបូងខាងលើនៅក្នុងកំឡុងពេលដែលច្បាប់កំណត់ បណ្តាលឱ្យអតិថិជនជនទទួលរងនូវការខូចខាតផលប្រយោជន៍ស្របច្បាប់របស់ខ្លួននោះ មេធាវីត្រូវទទួលខុសត្រូវសងការខូចខាត។ អាស្រ័យហេតុនេះ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីតម្រូវឱ្យមេធាវីបង់ប្រាក់ធានារ៉ាប់រងសម្រាប់ធានារ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនក្នុងវិជ្ជាជីវៈ ដើម្បីធានាការការពារផលប្រយោជន៍របស់អតិថិជន។[27]

### ឃ. សុចរិតភាព និងភាពស្មោះត្រង់

មេធាវីត្រូវកសាងជំនឿទុកចិត្តរបស់អតិថិជន។ ជាការពិតណាស់មេធាវីមិនអាចផ្តល់ជូនការធានាចំពោះអតិថិជនទាក់ទងនឹងលទ្ធផលវិជ្ជមាននៃរឿងក្តីឡើយ ប៉ុន្តែមេធាវីត្រូវខិតខំប្រឹងប្រែងបំពេញបេសកកម្មរបស់ខ្លួនឱ្យអស់ពីសមត្ថភាព។ ប្រសិនមេធាវីចង់បញ្ចប់បេសកកម្មរបស់ខ្លួនមុនពេលកំណត់ មេធាវីរូបនោះត្រូវជូនដំណឹងទៅអតិថិជនរបស់ខ្លួនអំពីការបញ្ឈប់ ឬការដកខ្លួនពីការបំពេញការងារនេះនៅក្នុងពេលវេលាមួយសមស្របដែលផ្តល់លទ្ធភាពឱ្យអតិថិជនអាចបង្ការផលប្រយោជន៍របស់ខ្លួន និងស្វែងរកមេធាវីផ្សេងទៀតដើម្បីឱ្យជួយការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួនវិញម្តង។[28] មេធាវីមិនត្រូវប្រើឧបាយកលដើម្បីទាញយកផលប្រយោជន៍ក្នុងស្ថានភាពដែលអតិថិជនមិនមានចំណេះដឹងផ្នែកច្បាប់ឡើយ។ មេធាវីត្រូវគោរពនិងប្រតិបត្តិនូវគោលការណ៍សុចរិតនិងភាពស្មោះត្រង់។[29]

### ង. ការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ

មេធាវីត្រូវដឹងកាតព្វកិច្ចរបស់ខ្លួនក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ។[30] ដោយហេតុថាការបំពានវិធានដែលពាក់ព័ន្ធនឹងការសម្ងាត់វិជ្ជាជីវៈអាចឱ្យមេធាវីទទួលនូវទណ្ឌកម្មជាបទវិន័យ និងផ្តន្ទាទោសព្រហ្មទណ្ឌ។[31]

---

[27] មាត្រា៧៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[28] មាត្រា២៩ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[29] មាត្រា៦ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[30] មាត្រា៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥ និងមាត្រា៧ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[31] មាត្រា៧៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥ និងមាត្រា ៣១៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣

មេធាវីមិនអាចបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាចត្រូវបានបង្ខំឱ្យបំពានលើការសម្ងាត់វិជ្ជាជីវៈរបស់ខ្លួន ទោះបីនៅមុខតុលាការក៏ដោយ។ ការសម្ងាត់នេះមិនត្រូវអាចឱ្យជនណាម្នាក់ស្រង់យកបានឡើយ ទោះបីជាអតិថិជនក៏ដោយ។

**ឧទាហរណ៍៖** មេធាវីមិនអាចនិយាយអង្គហេតុនៃរឿងក្តីរបស់អតិថិជនខ្លួនប្រាប់ទៅមិត្តភក្តិ គ្រួសារ ប្រព័ន្ធផ្សព្វផ្សាយ ឬជនណាម្នាក់ឡើយ។ ដោយត្រូវចាត់ទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ ការផ្តល់យោបល់ ឯកសារក្រៅផ្លូវការទាំងឡាយដែលមេធាវីតាក់តែងឡើងសម្រាប់អតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជនរបស់ខ្លួនផ្ញើទាក់ទងគ្នា។ ការរក្សាសម្ងាត់នៃវិជ្ជាជីវៈបានជួយការពារដល់ផលប្រយោជន៍ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អតិថិជនផងដែរ។ កាតព្វកិច្ចរបស់មេធាវី ក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ គឺជាកាតព្វកិច្ចក្នុងចំណោមកាតព្វកិច្ចដទៃទៀតដែលចងភ្ជាប់ទៅនឹងកាតព្វកិច្ចមានភាពស្មោះត្រង់ជាមួយអតិថិជន។ ក្រៅពីនេះ ការបំពេញកាតព្វកិច្ចទាំងនេះ បានជួយដល់ការកសាងទំនុកចិត្តរបស់អតិថិជនមកលើមេធាវី និងជួយសម្រួលដល់ការទាក់ទងគ្នាដ៏ល្អរវាងអតិថិជន និងមេធាវីរបស់ខ្លួនផងដែរ។

**ច. ទំនាស់ផលប្រយោជន៍ និងការហាមឃាត់**

ក្នុងគោលបំណងការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជន មេធាវីត្រូវហាមឃាត់ក្នុងការធ្វើជាមេធាវីការពារ ឬតំណាងឱ្យអតិថិជនក្នុងករណីដូចខាងក្រោម៖

- រឿងក្តីមួយដែលមេធាវីខ្លួនឯង ឬក្រុមមេធាវីរបស់ខ្លួន បានជួយបដិភាគីនៅក្នុងការផ្តល់យោបល់ ឬទទួលយល់ព្រមតំណាងឲ្យបដិភាគីរួចហើយ
- នៅពេលដែលផលប្រយោជន៍របស់អតិថិជនម្នាក់មានទំនាស់ជាមួយផលប្រយោជន៍របស់អតិថិជន ឬម្នាក់ទៀតនៅក្នុងរឿងក្តីដែលមេធាវី ឬក្រុមមេធាវីរបស់ខ្លួនកំពុងបំពេញភារកិច្ច
- នៅពេលដែលអតិថិជនទាំងពីរជាភាគីវិវាទនៅក្នុងរឿងក្តីតែមួយ
- នៅពេលដែលអតិថិជនម្នាក់ចង់ពឹងពាក់មេធាវី ឬក្រុមមេធាវីរបស់ខ្លួន តែមេធាវី ឬក្រុមមេធាវីនេះធ្លាប់បានទទួលជួយបដិភាគីក្នុងរឿងដទៃ ឬមេធាវីបានយល់ព្រមផ្តល់យោបល់ផ្នែកច្បាប់បន្តទៀត លើកលែងតែរឿងក្តីចុងក្រោយដែលមេធាវី ឬក្រុមមេធាវីដែលធ្លាប់ពាក់ព័ន្ធនោះបានកន្លងផុតទៅអស់រយៈពេល ២ ឆ្នាំ។
- រឿងក្តីមួយដែលមេធាវីឬក្រុមមេធាវីរបស់ខ្លួនបានដើរតួជា អាជ្ញាកណ្តាលអ្នកផ្សះផ្សា ឬសម្របសម្រួលក្នុងទម្រង់នីតិវិធីនៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។ ក្នុងករណីដែលមេធាវីឬក្រុមមេធាវីជាទីប្រឹក្សា ឬធ្លាប់ជាទីប្រឹក្សារបស់អតិថិជនច្រើនគ្នានោះ មេធាវីនឹងអាចទទួលការពារផលប្រយោជន៍ភាគីណាមួយបាន

លុះត្រាតែត្រូវបានជម្រាបជូនដំណឹងទៅភាគីឯទៀត និងបន្ទាប់ពីទទួលបានការយល់ព្រមជាមុន ហើយត្រូវប្រុងប្រយ័ត្នកុំឱ្យបាត់បង់នូវភាពថ្លៃថ្នូរ កិត្តិយស និងការសម្ងាត់វិជ្ជាជីវៈ។[32]

ដើម្បីធានាបាននូវការការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជន ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីក៏បានកំណត់ហាមឃាត់មិនឱ្យមេធាវី ដែលធ្លាប់ជាអតីតមន្ត្រីរាជការធ្វើបទអន្តរាគមន៍ការពារកូនក្តីប្រឆាំងនឹងក្រសួង មន្ទីររដ្ឋបាល ដែលខ្លួនស្ថិតនៅក្រោមឱវាទពីមុនដែរ។ មេធាវីនោះអាចធ្វើជាតំណាង ឬការពារកូនក្តីប្រឆាំងនឹងក្រសួង មន្ទីររដ្ឋបាល ដែលខ្លួនធ្លាប់ស្ថិតនៅក្រោមឱវាទបាន លុះត្រាតែផុតរយៈពេល ៥ឆ្នាំ គិតពីថ្ងៃដែលឈប់ពីមុខងាររបស់ខ្លួន។[33]

### ២.២.៣. ការបង់វិភាគទាន

គណៈមេធាវីមានឯករាជ្យភាពផ្នែករដ្ឋបាល និងស្វ័យភាពផ្នែកហិរញ្ញវត្ថុដាច់ដោយឡែកពីស្ថាប័នរដ្ឋាភិបាលទាំងឡាយ។ គណៈមេធាវីមិនចំណុះឱ្យអំណាចសាធារណៈ និងមិនប្រើប្រាស់ថវិកាជាតិដូចជាស្ថាប័នសាធារណៈដទៃទៀតឡើយ។ ផ្អែកតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងក្រមសីលធម៌មេធាវី មេធាវីទាំងអស់ដែលបច្ចុប្បន្នកំពុងមានឈ្មោះក្នុងបញ្ជីគណៈមេធាវីមានកាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវី។ គណៈមេធាវីប្រើប្រាក់ភាគទាននេះសម្រាប់ទ្រទ្រង់សកម្មភាព និងដំណើរការរដ្ឋបាលរបស់គណៈមេធាវី។ ភាគទាននេះត្រូវតែបង់ឱ្យបានទៀងទាត់ជាប្រចាំរាល់ត្រីមាសដោយត្រូវបង់នៅដំណាច់ត្រីមាសនីមួយៗ។ មេធាវីម្នាក់ៗត្រូវបង់ភាគទានឱ្យបានទាន់ពេលវេលាដែលបានកំណត់។ មេធាវីណាដែលមិនបានបង់ភាគទាន ត្រូវទទួលទណ្ឌកម្មហាមឃាត់មិនឱ្យប្រកបវិជ្ជាជីវៈមេធាវីឡើយ។[34]

[32] មាត្រា ២៥ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[33] មាត្រា ៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

[34] មាត្រា ៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

# ជំពូកទី២
# សិទ្ធិ និងតួនាទីរបស់មេធាវី
# ក្នុងសាលាជម្រះក្តីជាន់ទាប

# ជំពូកទី២
# សិទ្ធិ និងតួនាទីរបស់មេធាវីក្នុងសាលាជម្រះក្តីជាន់ទាប
## ផ្នែកទី១
## សិទ្ធិរបស់មេធាវីក្នុងសាលាជម្រះក្តីកម្ពុជា

### ១. សិទ្ធិក្នុងការបំពេញមុខងារវិជ្ជាជីវៈដោយគ្មានការជ្រៀតជ្រែក

មេធាវីអាចបំពេញមុខងារវិជ្ជាជីវៈទាំងអស់របស់ខ្លួនដោយគ្មានការបំភិតបំភ័យ ការបន្ទុចបង្អាក់ ការយាយី ឬការជ្រៀតជ្រែកដែលមិនត្រឹមត្រូវឡើយ ។[35] វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈដែលឯករាជ្យតែស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គណៈមេធាវីដែលជាស្ថាប័នឯករាជ្យ។ ឯក្សរាជ្យភាពនៃវិជ្ជាជីវៈមេធាវីមានន័យថា នៅពេលអនុវត្តវិជ្ជាជីវៈរបស់ខ្លួនមេធាវីម្នាក់ៗមិនស្ថិតនៅក្រោមបង្គាប់បញ្ជាដែលជាការជ្រៀតជ្រែក ឬការណែនាំពីបុគ្គលណាម្នាក់ឡើយ។

មេធាវី អាចធ្វើដំណើរ និងប្រឹក្សាយោបល់ជាមួយកូនក្តីរបស់ខ្លួនបានដោយសេរី ទាំងក្នុងប្រទេសនិងបរទេស ។[36] មេធាវីអាចធ្វើដំណើរទៅជួបពិភាក្សាជាមួយកូនក្តីរបស់ខ្លួនបានដោយសេរី ដោយគ្មានការហាមឃាត់ឡើយ មិនថាការជួបពិភាក្សានោះត្រូវធ្វើនៅក្រៅប្រទេសក៏ដោយ ក៏មេធាវីមានសិទ្ធិសេរីភាពពេញលេញក្នុងការធ្វើដំណើរទៅជួបពិភាក្សាដែរ។

មេធាវី មិនត្រូវបានទទួលរង ឬត្រូវបានគំរាមកំហែងដោយចោទប្រកាន់តាមផ្លូវតុលាការ ឬរដ្ឋបាល ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬទណ្ឌកម្មឯទៀត ចំពោះសកម្មភាពណាមួយដែលខ្លួនបានធ្វើ ស្របតាមបទដ្ឋានតួនាទី និងបទបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ឡើយ ។[37] រាល់សកម្មភាពរបស់មេធាវីដែលទាក់ទងទៅនិងការងារ ឬការប្រកបវិជ្ជាជីវៈដែលបានគោរពទៅតាមច្បាប់ ឬបទបញ្ញត្តិរបស់មេធាវី នោះមេធាវីមិនត្រូវទទួលបានការដាក់ទណ្ឌកម្មណាមួយមកលើខ្លួនឡើយ លើកលែងតែសកម្មភាពនោះបានផ្ទុយទៅនិងច្បាប់វិជ្ជាជីវៈទើបត្រូវបានទទួលរងនូវការដាក់ទណ្ឌកម្មពីក្រុមប្រឹក្សាគណៈមេធាវី ។

[35] ប្រការ ១៦ ចំណុច ក នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

[36] ប្រការ ១៦ ចំណុច ខ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

[37] ប្រការ ១៦ ចំណុច គ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

## ២. សិទ្ធិទទួលបានការការពារ

កាលបើមេធាវី ត្រូវបានគំរាមកំហែងដល់សន្តិសុខដោយសារតែការបំពេញតួនាទីរបស់ខ្លួននោះអាជ្ញាធរត្រូវតែផ្តល់ការការពារឲ្យបានគ្រប់គ្រាន់ដល់មេធាវីនោះ ។[38] មានន័យថា មេធាវីមានសិទ្ធិធ្វើការនៅក្នុងបរិយាកាសមួយដែលមានសុវត្ថិភាព ដោយគ្មានភាពភ័យខ្លាចដោយសារការគំរាមកំហែង ឬការបង្ខិតបង្ខំណាមួយឡើយ។

**ឧទាហរណ៍៖** នៅពេលដែលមេធាវី ចុះទៅសាកសួរពត៌មានពីកូនក្តីនៅក្នុងឃុំ មេធាវីត្រូវបានធានាថាមានសុវត្ថិភាព ហើយអាជ្ញាធរដែលមានសមត្ថកិច្ចនៅទីនោះត្រូវតែផ្តល់សុវត្ថិភាពជូនមេធាវី ហើយក៏អាចជួយក្នុងការសម្របសម្រួលដល់ការជួបគ្នារវាងមេធាវីជាមួយនិងកូនក្តី ដោយគ្មានការបង្កជាបញ្ហា ឬភាពរអាក់រអួលដោយប្រការណាមួយឡើយ។

មេធាវីមិនត្រូវក្លាយជាមុខសញ្ញាជាមួយកូនក្តីរបស់ខ្លួន ដោយសារតែការបំពេញតួនាទីរបស់ខ្លួនឲ្យកូនក្តីនោះឡើយ ។[39] ក្នុងពេលបំពេញមុខងារ ឬបន្ទាប់ពីបានបំពេញមុខងាររួច មេធាវីមិនត្រូវក្លាយជាមុខសញ្ញារបស់កូនក្តីដូចជា ការគំរាមកំហែង ឬការគុំគួន ដោយសារតែការមិនបានបំពេញតាមតម្រូវការ ឬការការពារក្តីមានលទ្ធផលអវិជ្ជមានដែលនាំឲ្យកូនក្តីមិនទទួលបានជោគជ័យ(ឈ្នះក្តី)នៅក្នុងពេលសវនាការ ។

## ៣. សិទ្ធិទទួលបានអភ័យឯកសិទ្ធិរដ្ឋប្បវេណី និងព្រហ្មទណ្ឌ

មេធាវីត្រូវមានអភ័យឯកសិទ្ធិពីបទព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ចំពោះសារណាការពារពាក់ព័ន្ធនានាដែលធ្វើក្នុងគោលបំណងសុចរិតក្នុងការការពារ ទោះជាលាយល័ក្ខណ៍អក្សរក្តី ជាផ្ទាល់មាត់ក្តី ឬក្នុងការបង្ហាញខ្លួនជាវិជ្ជាជីវៈរបស់ខ្លួន នៅចំពោះមុខតុលាការ សាលាក្តី ឬអាជ្ញាសាលាក្តី ឬអាជ្ញាធរច្បាប់ ឬរដ្ឋបាលផ្សេងទៀត ។[40] មេធាវីត្រូវមានអភ័យឯកសិទ្ធិ គឺសំដៅលើភាពមិនអាចផ្តន្ទាទោស ឬដាក់ពិន័យ និងមិនអាចរងនូវការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនឡើយ ដោយហេតុមកពីការការពារនានាដែលធ្វើឡើងដោយសុចរិតក្នុងកិច្ចការងារវិជ្ជាជីវៈរបស់ខ្លួន។

ក្នុងករណីខាងលើនេះ យើងអាចប្រៀបធៀបបានថា អភ័យឯកសិទ្ធិរបស់មេធាវីមានអត្ថន័យប្រហាក់ប្រហែលទៅនិងអភ័យឯកសិទ្ធិក្នុងគ្រួសារដែល ដែរអភ័យឯកសិទ្ធិក្នុងគ្រួសារបានចែងថា ចំពោះជនដែលបាន

[38] ប្រការ ១៧ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

[39] ប្រការ ១៨ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

[40] ប្រការ ២០ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

លួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ និងទ្រព្យសម្បត្តិរបស់សហព័ន្ធខ្លួននោះ មិនអាចផ្តន្ទាទោសព្រហ្មទណ្ឌពីអំពើលួចបានទេ។[41]

## ៤. សិទ្ធិក្នុងការតំណាងកូនក្តី

គ្មានតុលាការ ឬអាជ្ញាធររដ្ឋបាលណា ដែលបានទទួលស្គាល់សិទ្ធិមានស្មាក្តីហើយ បែរជាបដិសេធឈប់ទទួលស្គាល់នូវសិទ្ធិមានមេធាវីនៅចំពោះមុខសមត្ថកិច្ចខ្លួននោះឡើយ លុះត្រាតែមេធាវីនោះ មិនបានបំពេញលក្ខខណ្ឌស្របតាមច្បាប់ជាតិ និងការអនុវត្តជាក់ស្តែង ហើយមិនស្របជាមួយនឹងគោលការណ៍នេះ ។[42] មេធាវីអាចបដិសេធក្នុងការធ្វើជាអ្នកតំណាងកូនក្តីនៅក្នុងករណីណាមួយក៏បាន ក៏ប៉ុន្តែមេធាវីអាចទទួលបានការតំណាងឲ្យកូនក្តីបានដោយសេរី។ មេធាវីអាចតំណាងកូនក្តីណាម្នាក់ដោយមានការយល់ព្រមពីកូនក្តីនោះ។ កាលណាតុលាការបានទទួលស្គាល់មេធាវីដែលមានសិទ្ធិតំណាងកូនក្តីហើយ នោះតុលាការមិនអាចបដិសេធមេធាវីមិនឲ្យតំណាងឲ្យកូនក្តីបានទេ លុះត្រាតែមេធាវីនោះពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របច្បាប់ ទើបតុលាការមានសិទ្ធិបដិសេធបាន។

ចំណែកឯ តុលាការត្រូវគោរពសេចក្តីសម្រេចចិត្តរបស់កូនក្តីក្នុងការជ្រើសរើសមេធាវីតំណាង បើមិនដូច្នោះទេ មានន័យថា តុលាការគឺបានជ្រៀកជ្រែកដោយខុសច្បាប់ ចូលទៅក្នុងសិទ្ធិរបស់មេធាវី នៅក្នុងនីតិវិធីនៃការអនុវត្តវិជ្ជាជីវៈរបស់មេធាវី។

## ៥. សិទ្ធិទទួលបានកូនក្តី និងពត៌មានសម្រាប់ការពារកូនក្តី

អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងភ្លាមដល់បុគ្គលគ្រប់រូប ពីសិទ្ធិរបស់គេដែលអាចទទួលបានជំនួយពីមេធាវីម្នាក់ តាមការជ្រើសរើសរបស់គេក្រោយពីការចាប់ខ្លួន ឬឃុំខ្លួន ឬនៅពេលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ។[43] អាជ្ញាធរត្រូវផ្តល់ដំណឹងភ្លាម ឬពន្យល់ប្រាប់ជនជាប់ឃុំអំពីសិទ្ធិដែលអាចជ្រើសរើសមេធាវី ឬសិទ្ធិទទួលបានមេធាវីក្នុងករណីដែលកូនក្តីគ្មានលទ្ធភាពក្នុងការជ្រើសរើសមេធាវីសម្រាប់ជួយការពារក្តី។ បន្ទាប់ពីមានមេធាវី ឬបានជ្រើសរើសមេធាវីសម្រាប់ខ្លួនរួច នោះមេធាវីដែលត្រូវបានជ្រើសរើសត្រូវមានភារកិច្ចចូលទៅជួបកូនក្តី។ ការចូលទៅជួបកូនក្តីគឺបន្ទាប់ពីមានការឃាត់ខ្លួនអស់រយៈពេល ២៤ ម៉ោង ។[44] វាជាការងារមួយដ៏ចាំបាច់របស់មេធាវី ក្នុងការចូលទៅជួបកូនក្តីរបស់ខ្លួន ដើម្បីទំនាក់ទំនងគ្នាដែលជាពិសេសនោះគឺដើម្បីទទួលបាននូវមូលហេតុពិតប្រាកដនៃការចាប់ខ្លួនកូនក្តីរបស់ខ្លួន និងទទួលបានពត៌មាន

[41] មាត្រា ៣៩៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១១

[42] ប្រការ ១៩ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

[43] ប្រការ ៥ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

[44] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដែលអាចជាសញ្ញាណខ្លះៗសម្រាប់យកមកស្រាវជ្រាវបន្ថែមទាក់ទងទៅនិងរឿងក្តីរបស់កូនក្តី ដើម្បីជាភស្តុតាងក្នុងការជួយការពារកូនក្តីយ៉ាងមានប្រសិទ្ធិភាពនៅក្នុងពេលសវនាការ។

## ៦.សិទ្ធិមិនត្រូវចាត់ទុកថាមានចិត្តជាមួយកូនក្តី ឬបុព្វហេតុរបស់កូនក្តី

មេធាវីមានសិទ្ធិធានាអះអាងក្នុងការធានាដំណើរការភារកិច្ចរបស់ខ្លួន ដោយមិនត្រូវក្លាយជាមុខសញ្ញាជាមួយកូនក្តីរបស់ខ្លួនដោយសារតែការបំពេញតួនាទី អោយកូនក្តីនោះឡើយ ។[45] មានអត្ថន័យថា មេធាវីដែលតំណាងសិទ្ធិចំពោះកូនក្តីរបស់ខ្លួនពុំមានន័យថា មានការយល់ឃើញស្របជាមួយកូនក្តី ឬយល់ព្រមជាមួយជំនឿអត្តនោម័ត្ត ឬទង្វើរបស់កូនក្តី ទោះបីក្នុងហេតុផលណាមួយឡើយ។

**ឧទាហរណ៍៖** មេធាវីតំណាងសិទ្ធិឱ្យជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី គឺពុំមានន័យថាមេធាវីនោះមានចិត្តគាំទ្រចំពោះការប្រព្រឹត្តបទល្មើសនោះឬកំណត់ពីតម្លៃនៃការសងឡើយ ផ្ទុយទៅវិញមេធាវីត្រូវបានដើរតួនាទីស្វែងរកភស្តុតាងដោះបន្ទុកឱ្យកូនក្តីរបស់ខ្លួន និងប្រើប្រាស់សិទ្ធិទាំងឡាយដែលច្បាប់បានផ្តល់ជូនជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីទៅវិញទេ។

## ៧.សិទ្ធិក្នុងការទទួលបានការសំងាត់ផ្នែកវិជ្ជាជីវៈមេធាវី

រដ្ឋាភិបាលត្រូវទទួលស្គាល់ និងគោរពថា រាល់ការប្រាស្រ័យទាក់ទង និងការពិគ្រោះយោបល់រវាងមេធាវី និងកូនក្តីរបស់ពួកគេ នៅក្នុងទំនាក់ទំនងវិជ្ជាជីវៈរបស់ពួកគេជាការសំងាត់ ។[46] ពោល មេធាវី ក៏ដូចជាវេជ្ជបណ្ឌិតដែរ គឺអាចទទួលបាននូវទំនាក់ទំនងជាសំងាត់ជាមួយនឹងអតិថិជនរបស់ខ្លួន។ ការផ្តល់ ឬប្រើប្រាស់មធ្យោបាយណាមួយដែលប្រែក្លាយការសន្ទនារវាងមេធាវី និងកូនក្តីរបស់ខ្លួនឱ្យបើកចំហរ គឺជាមធ្យបាយផ្ទុយនឹងច្បាប់។ មួយវិញទៀត រាល់ការចំលងឯកសារ ឬការថតសំលេងដោយសំងាត់ គឺជាកម្មវត្ថុនៃការដាក់ទណ្ឌកម្ម ឬផ្តល់នូវភស្តុតាងដោយសុវត្ថិភាព។ មិនត្រឹមតែប៉ុណ្ណោះ គឺគ្មានមេធាវីណាមួយត្រូវបានគេបង្ខំឱ្យបើកកកាយអំពីការប្រាស្រ័យទាក់ទងរបស់ខ្លួនជាមួយនឹងកូនក្តីនោះឡើយ។ ជាក់ស្តែង មាត្រា ៩៨ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានធានាសិទ្ធិរបស់មេធាវីក្នុងការសន្ទនាដោយសម្ងាត់រយៈពេល ៣០នាទី ជាមួយបុគ្គលដែលត្រូវឃាត់ខ្លួនផងដែរ ។[47]

---

[45] ប្រការ ១៨ នៃគោលការណ៍មូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

[46] ប្រការ ២២ នៃគោលការណ៍មូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

[47] មាត្រា ៩៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មួយវិញទៀត សូម្បីតែបទប្បញ្ញត្តិស្តីពីការឆែកឆេរនៅក្នុងការិយាល័យមេធាវីក៏ត្រូវបានច្បាប់ធានាដោយវិធានពិសេសជាងការឆែកឆេរលើលំនៅដ្ឋានរបស់បុគ្គលទូទៅដែរ ដោយការឆែកឆេរដាច់ខាតត្រូវតែធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមីជាដើម ។[48]

## ៨.សិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគមន៍

មេធាវី ក៏ដូចជាប្រជាពលរដ្ឋទូទៅដែរ មានសិទ្ធិទទួលាបនសេរីភាពនៃការសំដែងមតិ ជំនឿ ការបង្កើតសមាគម និងការជួបប្រជុំ។ ជាពិសេស មេធាវីត្រូវមានសិទ្ធិចូលរួមជាសាធារណៈក្នុងការពិភាក្សាបញ្ហាច្បាប់ រដ្ឋបាលយុត្តិធម៌ និងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ព្រមទាំងចូលរួម ឬបង្កើតជាអង្គការតាមមូលដ្ឋាន អង្គការជាតិ និងអន្តរជាតិ ក៏ដូចជាចូលរួមការប្រជុំរបស់ខ្លួន ដោយមិនទទួលរងនូវការរឹតត្បិតវិជ្ជាជីវៈ ដោយសារហេតុផលនៃសកម្មភាពស្របច្បាប់ ឬសមាជិកភាពរបស់ខ្លួន នៅក្នុងក្នុងអង្គការស្របច្បាប់ណាមួយឡើយ។ ក្នុងការអនុវត្តសិទ្ធិទាំងនេះ ជានិច្ចកាល មេធាវីត្រូវតែធ្វើខ្លួនឱ្យស្របតាមច្បាប់ ព្រមទាំងបទដ្ឋាន និងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ ។[49] ប្រការនេះ មានន័យថា មេធាវីអាចចូលរួមនៅក្នុងអង្គការជាតិរួមមានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការអន្តរជាតិដើម្បីលើកកម្ពស់ និងអភិវឌ្ឍន៍នៃវិជ្ជាជីវៈមេធាវី។ មិនត្រឹមតែប៉ុណ្ណោះ ការចូលរួមសមាគមរបស់មេធាវី គឺបានជួយឱ្យពួកលើកកម្ពស់ ការពារ និងពង្រឹងសិទ្ធិមនុស្សនៅក្រោមនីតិរដ្ឋ និងដើម្បីរក្សាភាពឯករាជ្យនៃតុលាការផងដែរ។

## ៩.សិទ្ធទទួលបានការអប់រំ និងការបណ្តុះបណ្តាល

រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវី និងគ្រឹះស្ថានសិក្សា ត្រូវធានាថា មេធាវីមានការអប់រំ និងការបណ្តុះបណ្តាលសមស្រប និងត្រូវឱគេយល់ច្បាស់អំពីឧត្តមគតិ និងករណីកិច្ចផ្នែកសីលធម៌របស់មេធាវី និងករណីកិច្ចនៃសិទ្ធិមនុស្ស ព្រមទាំងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ ។[50]

ជាក់ស្តែង នៅក្នុងឆ្នាំ ២០០២ គណៈមេធាវីកម្ពុជាបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវីសម្រាប់អនុវត្តកម្មវិធីចូលជាសមាជិកគណៈមេធាវីក្នុងការចេញអាជ្ញាបណ្ណដល់មេធាវីថ្មីនៅក្នុងប្រទេសកម្ពុជា។ សាលានេះត្រូវបានបើកជាផ្លូវការនៅចុងខែតុលា ឆ្នាំ ២០០២ ដោយមានសិស្សចំនួន ៦០នាក់ ដែលផ្តោតលើការសរសេរកិច្ចសន្យា ជំនាញក្នុងការទំនាក់ទំនង ការចរចារ និងការសម្រុះសម្រួល និងច្បាប់ពាណិជ្ជកម្ម។ ដោយឡែក តាមស្ថិតិរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានបង្ហាញរហូតមកដល់ត្រឹមថ្ងៃទី ០២ ខែកក្កដា

---

48 មាត្រា ៩១ វាក្យខណ្ឌទី ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

49 ប្រការ ២៣ នៃគោលការណ៍មូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

50 ប្រការ ៩ នៃគោលការណ៍មូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

ឆ្នាំ២០២១ សមាជិក សមាជិកាគណៈមេធាវី មានចំនួនសរុប ១៨៤៦រូប មេធាវីកំពុងធ្វើកម្មសិក្សាសរុបមានចំនួន ៣៣០រូប ដោយតាមរយៈការវិវត្តន៍នៃចំនួនសមាជិកគណៈមេធាវីនេះបានបញ្ជាក់ឱ្យឃើញថា រដ្ឋាភិបាលកម្ពុជាបានគិតគូរពីការអភិវឌ្ឍន៍ដោយយកចិត្តទុកដាក់ចំពោះការអប់រំ និងការបណ្តុះបណ្តាលមេធាវីយ៉ាងល្អប្រសើរ និងតម្លាភាពរហូតដល់បច្ចុប្បន្ន។[51]

## ១០.មេធាវីមានសិទ្ធិទទួលបានមេធាវីម្នាក់ទៀតដើម្បីផ្តល់ជាជំនួយដល់ខ្លួន

ក្នុងករណីចាំបាច់មេធាវីដែលទទួលបេសកកម្មពីអតិថិជនអាចផ្ទេរបេសកម្មនោះទាំងស្រុង ឬមួយភាគទៅឱ្យសហភាតាណាមួយធ្វើជាអនុតំណាងដើម្បីបំពេញបេសកកម្មរបស់ខ្លួនបាន ប៉ុន្តែការផ្ទេរនេះអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីកូនក្តីរបស់ខ្លួនផងដែរ ។[52] រីឯ ភារកិច្ចរបស់អនុតំណាងគឺត្រូវសហការជា ដៃគូរជំនួយដល់មេធាវីដើមនោះ ដោយវិសាលភាពនៃកិច្ចការគឺដូចគ្នាទាំងស្រុងនឹងមេធាវីដើមផងដែរ។

ជាទូទៅ មូលហេតុដែលច្បាប់ផ្តល់អត្តិភាពដល់មេធាវី ដើម្បីមានសិទ្ធិទទួលបានមេធាវីម្នាក់ទៀត គឺក្រោមហេតុផលដោយសារតែ រឿងក្តីមានលក្ខណៈស្មុគស្មាញពេកក្នុងការស្វែងរកភស្តុតាងដែលរឹងមាំ ឬ ការស្រាវជ្រាវអង្គច្បាប់សម្រាប់លើកឡើងជាដំណោះស្រាយដើម្បីការពារផលប្រយោជន៍កូនក្តីដោយជាក់លាក់ ឬក៏អាចជាហេតុផលធ្វើឱ្យដំណើរការសិក្សាលើរឿងក្តីមានភាពឆាប់រហ័សដើម្បីជៀសវាងការកាន់តែខាតបង់នៃពេលវេលា និងតម្លៃនៃកម្មវត្ថុបណ្តឹងដែលចាំបាច់ខ្លាំងសម្រាប់កូនក្តីផងដែរ។

## ១១.សិទ្ធិទទួលបានការផ្តល់ពត៌មានសម្រាប់កូនក្តីរបស់ខ្លួន

អាជ្ញាធរមានសមត្ថកិច្ចមានតួនាទីត្រូវធានាឱ្យ មេធាវីមានសិទ្ធិទទួលបានពត៌មានដែលសមស្របសំណុំរឿង និងឯកសារនៅក្នុងការកាន់កាប់ ឬការគ្រប់គ្រងរបស់ខ្លួន ដើម្បីឱ្យមេធាវីមានពេលវេលាគ្រប់គ្រាន់អាចផ្តល់ជំនួយផ្នែកច្បាប់ដល់កូនក្តីរបស់ខ្លួន ប្រកបដោយប្រសិទ្ធិភាព។ សិទ្ធិទទួលបាននេះ គួរតែផ្តល់ឱ្យនៅពេលវេលាសមស្របឆាប់បំផុត ។[53] ជាក់ស្តែង រឿងក្តីរដ្ឋប្បវេណីត្រង់បញ្ញត្តិស្តីពីការទទួលខុសត្រូវរបស់តុលាការ និងភាគី បានជម្រុញឱ្យតុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្តឹងឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័សផងដែរ ។[54]

[51] អំណះអំណាង https://www.bakc.org.kh/index.php/km/2017-07-24-08-31-04
ចូលមើលនៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២១

[52] មាត្រា ៤៧ ក្រមសីលធម៌មេធាវី នៃគណៈមេធាវី ឆ្នាំ២០១២

[53] ប្រការ ៩ នៃគោលការណ៍មូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

[54] មាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ជាក់ស្តែង មេធាវីមានសិទ្ធិពិនិត្យមើលសំណុំរឿងនៃរបាយការណ៍កោសលវិច័យ។ ប្រសិនមេធាវីយល់ឃើញថាការធ្វើកោសលវិច័យនោះមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់តាមលក្ខណៈបច្ចេកទេស មេធាវីត្រូវស្នើសុំទៅចៅក្រមស៊ើបសួរដើម្បីធ្វើប្រតិកោសលវិច័យ ឬកោសលវិច័យបន្ថែមបាន ។

# ផ្នែកទី២

# តួនាទីរបស់មេធាវីក្នុងសាលាជម្រះក្តីជាន់ទាប

## ១. តួនាទីក្នុងរឿងក្តីព្រហ្មទណ្ឌ

ដោយសារតែមេធាវីដើរតួយ៉ាងសំខាន់ក្នុងដំណើរការចូលរួមស្វែងរកយុត្តិធម៌ដ៏ត្រឹមត្រូវ ហើយជាការសំខាន់ណាស់ដែលមេធាវីត្រូវបានអនុញ្ញាតឱ្យធ្វើតាមមុខងារ ឬតួនាទីរបស់ពួកគេ ដោយគ្មានការដាក់កំណត់តឹងតែង ឬ ជ្រៀតជ្រែកអ្វីឡើយ។ ការបកស្រាយខាងក្រោមនេះនឹងបង្ហាញពីតួនាទីរបស់មេធាវីនៅក្នុងដំណាក់កាលនានា ក្នុងនីតិវិធីព្រហ្មទណ្ឌដែលតម្រូវឱ្យមានមេធាវីការពារដើម្បីការពារដល់ជនគ្រប់រូបដែលមានការពាក់ព័ន្ធក្នុងរឿងព្រហ្មទណ្ឌ ។

### ១.១. តួនាទីរបស់មេធាវីមុនពេលជំនុំជម្រះ

#### ១.១.១. ការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ ឬនគរបាលតុលាការ គឺជាជំនួយការតុលាការ។ ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេតក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌នូវសិទ្ធិដើម្បីឃាត់ខ្លួនជនមួយចំនួនដែលសង្ស័យថា បានចូលរួមក្នុងការប្រព្រឹត្តបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនបានតែក្នុងរយៈពេល ៤៨ ម៉ោងតែប៉ុណ្ណោះ។[55] កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឱ្យដឹងពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួននោះ។ ជាពិសេសមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់សាមីជនពីសិទ្ធិដែលអាចទទួលបានជំនួយពីមេធាវីក្នុងអំឡុងពេលឃាត់ខ្លួននោះ។[56]

ក្នុងរយៈពេលនេះ មេធាវីមានភារកិច្ចចូលទៅជួបកូនក្តីរបស់ខ្លួន បន្ទាប់ពីមានការជ្រើសរើសពីកូនក្តី ឬតាមរយៈការចាត់តាំងពីតុលាការ។ ការចូលទៅជួបកូនក្តីគឺបន្ទាប់ពីមានការឃាត់ខ្លួនអស់រយៈពេល ២៤ម៉ោង។ វាជាការងារមួយដ៏ចាំបាច់របស់មេធាវី ក្នុងការចូលទៅជួបកូនក្តីរបស់ខ្លួនដើម្បីទាក់ទងគ្នា ដែលជាពិសេសនោះគឺដើម្បីទទួលបាននូវមូលហេតុពិតប្រាកដនៃការឃាត់ខ្លួនកូនក្តីរបស់ខ្លួន។ ក្នុងរយៈពេលនេះមេធាវីធ្វើការសន្ទនាជាមួយកូនក្តីបានរយៈពេល ៣០ (សាមសិប) នាទី ដោយចូលទៅកាន់កន្លែងដែលឃាត់ខ្លួននោះ ហើយរាល់ការ

[55] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[56] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សន្ធនាត្រូវស្ថិតក្នុងលក្ខខ័ណ្ឌធានានូវការសម្ងាត់។[57] ក្នុងរយៈពេលនៃការជួបជាមួយកូនក្តីមេធាវីត្រូវបង្កើតទំនាក់ទំនងនៃសេចក្តីទុកចិត្ត និងការជឿជាក់ជាមួយកូនក្តី ពីព្រោះវាមានសារៈសំខាន់ណាស់ដែលកូនក្តីបង្ហាញហេតុការណ៍ទាំងឡាយមកឱ្យមេធាវី ដើម្បីឱ្យមេធាវីអាចត្រៀមលក្ខណៈរៀបចំការពារដោយមានប្រសិទ្ធិភាព ។

ដោយហេតុតែក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានកំណត់នូវបញ្ញត្តិមួយចំនួនដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតពេលបំពេញមុខងារ ហើយជាពិសេសមានបទបញ្ញត្តិមួយចំនួនដែលទាមទារឱ្យមន្ត្រីនគរបាលយុត្តិធម៌ទាំងនោះត្រូវតែគោរពដាច់ខាត បើមិនដូច្នោះទេកិច្ចការនានាដែលបានធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌នោះត្រូវមោឃភាពចោល។[58] ដូចនេះហើយ ត្រង់នេះជាចំណុចដែលមេធាវីការពារត្រូវពិនិត្យ និងស្រាវជ្រាវនូវកិច្ចទាំងឡាយណាដែលមន្ត្រីនគរបាលយុត្តិធម៌អនុវត្តដោយមិនគោរពបទបញ្ញត្តិទាំងនោះ រួមមាន៖

- មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។[59]
- ការឆែកឆេរ របស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានការអនុញ្ញាតជាមុនពីព្រះរាជអាជ្ញា។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ត្រូវធ្វើនៅចំពោះមុខសាក្សី ២ នាក់ ដែលសាក្សីនោះមិនមែនជានគរបាល ឬ កងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការ។ ការឆែកឆេរមិនអាចចាប់ផ្តើមមុនម៉ោង ៦ ព្រឹក និង ក្រោយម៉ោង ១៨ ល្ងាចឡើយ លើកលែងតែមានបទបញ្ញត្តិពិសេស ។[60]
- មន្ត្រីនគរបាលយុត្តិធមិត្រូវបិទស្លាក និង បោះត្រាលើវត្ថុតាង និង បង្ហាញដល់អ្នកកាន់កាប់ទីកន្លែង ឬ ដល់សាក្សីពីរនាក់មើល រួចត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ និង មានចុះហត្ថលេខា ឬ ផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬ ដោយសាក្សីពីរនាក់។ [61]
- ការស្តាប់ចម្លើយនីមួយៗត្រូវមានធ្វើកំណត់ហេតុ និង ត្រូវដកស្រង់ដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ។ ទំព័រនីមួយៗនៃកំណត់ហេតុត្រូវចុះហត្ថលេខា ឬ ផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ។ [62]

---

[57] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[58] មាត្រា ១០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[59] មាត្រា ៩០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[60] មាត្រា ៩១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[61] មាត្រា ៩២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[62] មាត្រា ៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

• មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន។ បញ្ជាឱ្យចូលខ្លួនត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ កាលបរិច្ឆេទ និង ហត្ថលេខារបស់ព្រះរាជអាជ្ញា និងបោះត្រា។[63]

• មន្ត្រីនគរបាលយុត្តិធម៌ត្រូវពឹងពាក់ដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ក្នុងការធ្វើការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រដោយមិនអាចបង្អង់បាន ។[64]

• ការឃាត់ខ្លួនដោយនគរបាលយុត្តិធម៌មិនអាចលើសពីរយៈពេល ៤៨ ម៉ោងបានទេ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន ដោយមានចុះហត្ថលេខា ឬ ផ្តិតស្នាមម្រាមដៃរបស់ជនត្រូវឃាត់ខ្លួន ។[65]

• មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឱ្យមេធាវីចូលជួបជនដែលត្រូវបានឃាត់ខ្លួន បន្ទាប់ពីរយៈពេល២៤ ម៉ោង និង ស្ថិតក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនា ។[66]

• មន្ត្រីនគរបាលយុត្តិធម៌អាចអនុញ្ញាតឲ្យ គ្រូពេទ្យពិនិត្យដល់ជនដែលត្រូវបានឃាត់ខ្លួនបានគ្រប់ពេលវេលា និង ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញា។[67]

• កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬ ដល់អ្នកទទួលភារកិច្ចលើអនីតិជននោះ ។[68]

• មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យស្តាប់ ថតសម្លេងការសន្ទនាតាមទូរស័ព្ទ និងបង្គាប់ឲ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ឡើយ ។[69]

• ចំពោះបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការស៊ើបអង្កេតលើសពីរយៈពេល ៧ថ្ងៃ និងត្រូវប្រព្រឹត្តទៅជាប់ជានិច្ចក្រោយពេលដែលបទល្មើសជាក់ស្តែង ឬការចាត់ទុកដូចជាបទល្មើសជាក់ស្តែងបានកើតឡើង។ ក្រោយការបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ វត្ថុតាង

[63] មាត្រា ៩៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[64] មាត្រា ៩៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[65] មាត្រា ៩៦ និងមាត្រា ៩៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[66] មាត្រា ៩៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[67] មាត្រា ៩៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[68] មាត្រា ១០០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[69] មាត្រា ១០៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ទាំងអស់ និង បុគ្គលដែលឃាត់ខ្លួនទៅព្រះរាជអាជ្ញា។ កំណត់ហេតុត្រូវមានឈ្មោះ ឋានៈអង្គភាព ហត្ថលេខារបស់មន្ត្រីនោះ និងកាលបរិច្ឆេទ ។[70]

### ១.១.២. ការចោទប្រកាន់ និង ស៊ើបអង្កេត

ព្រះរាជអាជ្ញាគឺជាអ្នកធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់។ នៅពេលដែលរឿងក្ដីស្ថិតក្នុងដៃព្រះរាជអាជ្ញា មានន័យថារឿងដែលកើតឡើងនោះ ព្រះរាជអាជ្ញាពុំទាន់បានធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងទៅចៅក្រមស៊ើបសួរឡើយ។ ម្យ៉ាងវិញទៀត ការចោទប្រកាន់របស់ព្រះរាជអាជ្ញាអាចធ្វើតាមការបើកការស៊ើបសួរ ឬការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម អាស្រ័យតាមលក្ខខណ្ឌនៃបទល្មើស ។[71]

ក្នុងដំណាក់កាលនេះហើយដែលមេធាវីត្រូវមានទំនាក់ទំនងជាមួយព្រះរាជអាជ្ញាដើម្បីផ្ដល់ឯកសារជាភស្តុតាង ជាសាក្សី ឬនិយាយរៀបរាប់ពីដំណើរហេតុនៃរឿងដើម្បីឱ្យព្រះរាជអាជ្ញាពិចារណាទៅតាមផ្លូវច្បាប់ថាតើរឿងនោះជាប្រភេទបទល្មើសអ្វី ឬរឿងនោះមានពិរុទ្ធភាពសមល្មមសម្រាប់ចោទប្រកាន់ឬនៅ ឬរឿងនោះគ្មានពិរុទ្ធភាពដើម្បីចោទប្រកាន់។ ការធ្វើបែបនេះ ដើម្បីឱ្យមានការចោទប្រកាន់កូនក្ដីឱ្យបានត្រឹមត្រូវតាមអំពើដែលកូនក្ដីបានប្រព្រឹត្ត ចៀសវាងការខ្វះមូលដ្ឋាន ឬទទួលបានមូលដ្ឋានមិនពិតដែលអាចធ្វើឱ្យកូនក្ដីរបស់ខ្លួនទទួលភាពអយុត្តិធម៌ជាដើម។

### ១.១.៣. ការស៊ើបសួរ

ភាពចាំបាច់របស់ចៅក្រមស៊ើបសួរ ត្រូវបានបែងចែកដាច់ពីចៅក្រមជំនុំជម្រះ។ ចៅក្រមស៊ើបសួរមានតួនាទីសំខាន់ក្នុងការសម្រេចថា តើត្រូវបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ចៅក្រមស៊ើបសួរមានភារកិច្ចសំខាន់ផងដែរ ក្នុងការធានាឱ្យមានការអនុវត្តនីតិវិធីត្រឹមត្រូវទៅតាមច្បាប់នៅពេលធ្វើការស៊ើបសួរ ដោយបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញការពិត ។[72]

ក្នុងរឿងក្ដីព្រហ្មទណ្ឌភាគច្រើន មេធាវីមានឱកាសចូលរួមចាប់ពីនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ ក្នុងរយៈពេលនេះមេធាវី ត្រូវទំនាក់ទំនងជាមួយចៅក្រមស៊ើបសួរដើម្បីពិនិត្យមើលឯកសារសំណុំរឿងទាំងឡាយ ដែលខ្លួនយល់ឃើញថាមានការពាក់ព័ន្ធដល់កូនក្ដីរបស់ខ្លួន។ ហើយមេធាវី អាចពិនិត្យមើលនូវការចាប់ផ្ដើមការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ថាតើការស៊ើបសួរនេះ ត្រូវបានធ្វើឡើងដោយមានដីកា

---

[70] មាត្រា ១០៦ មាត្រា ១០៧ និងមាត្រា ១០៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[71] មាត្រា ៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[72] មាត្រា ១២៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាដែរឬទេ ពីព្រោះចៅក្រមស៊ើបសួរគ្មានតួនាទីធ្វើការស៊ើបសួរលើបណ្តឹងណាមួយដោយឯកឯងបានឡើយ ទោះបីខ្លួនបានទទួលពាក្យបណ្តឹងដោយផ្ទាល់ក៏ដោយ ពោលគឺត្រូវបញ្ជូនបណ្តឹងនោះទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់ជាមុនសិន ។[73]

## ក. ការសួរចម្លើយ និង ការស្តាប់ចម្លើយ

### ក.១. ការសួរចម្លើយជនត្រូវចោទ

បន្ទាប់ពីបានទទួលការកោះហៅពីចៅក្រមស៊ើបសួរ ពីពេលវេលានៃការសួរចម្លើយជនត្រូវចោទនោះ មេធាវីត្រូវរៀបចំពិនិត្យមើលសំណុំរឿងនៃនីតិវិធី រួមជាមួយនឹងការត្រៀមមធ្យោបាយការពារផ្សេងៗទៀតដែលខ្លួនយល់ថា ជាការដោះបន្ទុកចំពោះកូនក្តីរបស់ខ្លួន។

ក្នុងពេលសួរចម្លើយជនត្រូវចោទ មេធាវីការពារត្រូវអមជាមួយជនត្រូវចោទ ប្រសិនបើជនត្រូវចោទទាមទារឱ្យមានមេធាវីការពារ។

ការសួរចម្លើយ គឺជានីតិវិធីមួយដែលចាំបាច់ដើម្បីឱ្យជនត្រូវចោទបង្ហាញនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្តហេតុនេះហើយចៅក្រមស៊ើបសួរធ្វើការសួរចម្លើយដោយផ្ទាល់ដល់ជនត្រូវចោទ។ ក្នុងដំណាក់កាលនេះហើយដែលមេធាវីត្រូវត្រៀមស្តាប់នូវសំណួររបស់ចៅក្រម ថាតើជាប្រភេទសំណួរដែលដាក់បន្ទុកបង្ខំឱ្យជនត្រូវចោទឆ្លើយសារភាពដាក់កំហុសលើខ្លួនឯងឬទេ ឬជាសំណួរដែលមិនមានការពាក់ព័ន្ធក្នុងអង្គហេតុ។ បើដូច្នេះមែន មេធាវីត្រូវតវ៉ាភ្លាមប្រសិនបើចៅក្រមសួរនូវសំណួរទាំងឡាយនេះ។ ម្យ៉ាងទៀត មេធាវីត្រូវរៀបចំលក្ខណៈឱ្យបានគ្រប់គ្រាន់ដើម្បីឆ្លើយ ដោះបន្ទុកចំពោះសំណួរទាំងឡាយរបស់ចៅក្រមស៊ើបសួរ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំចៅក្រមស៊ើបសួរចូលរួមជាមួយ នៅពេលសួរចម្លើយជនត្រូវចោទ។ ប្រសិនបើមេធាវីយល់ឃើញថា មានប្រយោជន៍ដល់កូនក្តីរបស់ខ្លួន មេធាវីអាចលើកសំណួរដោយមានការយល់ព្រមពីចៅក្រមស៊ើបសួរជាមុនសិន។

### ក.២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី អាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះបាន ដោយអ្នកតំណាងស្របច្បាប់របស់ខ្លួនកាលណាជនរងគ្រោះនេះជាអនីតិជន ឬនីតិជនដែលស្ថិតក្រោមរបបច្បាប់ការពារ។

មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលការកោះហៅពីចៅក្រមស៊ើបសួរ និងពេលវេលានៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរៀបចំពិនិត្យមើលនូវសំណុំរឿងនៃនីតិវិធី។ មេធាវីត្រូវត្រៀមរៀបចំ

[73] មាត្រា ១២៤ វាក្យខណ្ឌទី ៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឯកសារ ឬភស្តុតាងទាំងឡាយណាដែលខ្លួនប្រមូលបាន ដើម្បីបង្ហាញទៅចៅក្រមស៊ើបសួរសម្រាប់ជាប្រយោជន៍ដល់កូនក្តីរបស់ខ្លួន ។

ក្នុងពេលស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមេធាវីត្រូវអមជាមួយដើមបណ្តឹងរដ្ឋប្បវេណីជានិច្ច ប្រសិនបើមានការស្នើសុំពីដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីត្រូវបង្ហាញនូវគ្រប់មធ្យោបាយ និងភស្តុតាងនានាដែលខ្លួនមានដាក់ជូនទៅចៅក្រមស៊ើបសួរ ក្នុងការទទួលបានជាផលប្រយោជន៍ដល់កូនក្តីរបស់ខ្លួន។

មេធាវីការពាររបស់ជនត្រូវចោទ អាចស្នើសុំចៅក្រមស៊ើបសួរដើម្បីចូលរួមនៅក្នុងពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបាន។ ប្រសិនបើខ្លួនយល់ឃើញថាមានប្រយោជន៍ដល់កូនក្តីរបស់ខ្លួន មេធាវីនោះអាចលើកជាសំណួរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរជាមុនសិន ។

## ក.៣. ការស្តាប់ចម្លើយសាក្សី

សាក្សីជាជនទាំងឡាយដែលបានឃើញ បានឮ នូវហេតុការណ៍ដោយផ្ទាល់ ឬ ដោយប្រយោល។ ការដែលជនណាម្នាក់បានដឹងនូវព្រឹត្តិហេតុ ដូចនេះជាការចាំបាច់សម្រាប់ចៅក្រមដើម្បីធ្វើការសាកសួរចម្លើយជននោះដោយខានមិនបាន ព្រោះវាជាភស្តុតាងមួយសម្រាប់ដាក់បន្ទុក ឬដោះបន្ទុកឱ្យពិរុទ្ធជន។ ភស្តុតាងជាចម្លើយរបស់សាក្សី អាចជាផលប្រយោជន៍ដល់ជនរងគ្រោះ ឬដល់ពិរុទ្ធជន។

ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសម្តែងឱ្យឃើញការពិត។ ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ចៅក្រមស៊ើបសួរក៏អាចសួរ តទល់គ្នា រវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបានផងដែរ ។[74]

បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែមកបង្ហាញខ្លួន។ ចៅក្រមស៊ើបសួរចេញដីកាបញ្ជាឱ្យចូលមកបង្ហាញខ្លួនបាន ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈ បង្ខំសាក្សីនេះឱ្យចូលមកបង្ហាញខ្លួនបាន ។[75] ប្រសិនបើសាក្សីដាក់បន្ទុកខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខតុលាការទេនោះ តំណាងអយ្យការប្រហែលជាមិនអាចបង្ហាញភស្តុតាងរបស់ខ្លួនក្នុងការចោទប្រកាន់បានឡើយ ហើយដែលអាចបណ្តាលឱ្យការចោទប្រកាន់របស់អយ្យការបរាជ័យ។

ដូចគ្នានេះដែរ មេធាវីការពារមានសិទ្ធិអញ្ជើញ ឬហៅសាក្សីរបស់ខ្លួន ដែលជាសាក្សីដែលមេធាវីយល់ថានឹងផ្តល់ភស្តុតាង ជាផលប្រយោជន៍ដល់កូនក្តី មកបំភ្លឺនៅ តុលាការបានដូចគ្នា។

[74] មាត្រា ១៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[75] មាត្រា ១៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ខ. ការធ្វើកោសលវិច្ឆ័យ

ក្នុងដំណាក់កាលនៃការស៊ើបសួរ ពេលដែលចៅក្រមស៊ើបសួរប្រមូលបាននូវវត្ថុតាងដែលមានការពាក់ព័ន្ធអំពើល្មើសហើយពុំអាចធ្វើការវាយតម្លៃដោយខ្លួនឯងបាន នោះចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯងបាន ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ឬជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវចាត់តាំងអ្នកជំនាញណាម្នាក់ឱ្យមកពិនិត្យ និងវាយតម្លៃលើវត្ថុតាងនោះ ។[76]

មេធាវីការពារត្រូវចូលរួមជាមួយកូនក្តីរបស់ខ្លួន ក្នុងកំឡុងពេលដែលអ្នកជំនាញត្រូវការស្តាប់ចម្លើយជនត្រូវចោទ ប៉ុន្តែបើចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬ អ្នកចិត្តសាស្ត្រ ដើម្បីពិនិត្យជនត្រូវចោទ នោះការពិនិត្យវេជ្ជសាស្ត្រ ឬ ចិត្តសាស្ត្រ គឺមិនតម្រូវឱ្យមានការចូលរួមពីមេធាវីទេ ។[77]

មេធាវីត្រូវតាមដានមើលនូវដំណើរការនៃការស្តាប់ចម្លើយនេះ ថាតើអ្នកជំនាញអនុវត្តទៅតាមនីតិវិធីដែរឬទេ ប្រសិនបើមេធាវីយល់ឃើញថាខុសនីតិវិធី ឬក៏អ្នកជំនាញបង្ខំឱ្យជនត្រូវចោទនិយាយបង្ហាញនូវអំពើទាំងឡាយដែលខ្លួនបានប្រព្រឹត្ត នោះមេធាវីត្រូវធ្វើការជំទាស់ទៅនឹងការស្តាប់ចម្លើយនោះភ្លាម។

កាលណារបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា។ របាយការណ៍នៃកោសលវិច័យនេះ ត្រូវដាក់ចូលក្នុងសំណុំរឿង។ ចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី ដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ។

មេធាវីត្រូវពិនិត្យមើលសំណុំរឿងនៃរបាយការណ៍កោសលវិច័យ។ ប្រសិនមេធាវីយល់ឃើញថាការធ្វើកោសលវិច័យនោះមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់តាមលក្ខណៈបច្ចេកទេស មេធាវីត្រូវស្នើសុំទៅចៅក្រមស៊ើបសួរដើម្បីធ្វើប្រតិកោសលវិច័យ ឬកោសលវិច័យបន្ថែមបាន។ រយៈពេលនៃការដាក់ពាក្យឱ្យធ្វើប្រតិកោសលវិច័យនេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដែលរយៈពេលនេះមិនអាចតិចជាង ១០ថ្ងៃ ឡើយ ។[78]

### គ. ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលជាលិខិតផ្លូវការរបស់ចៅក្រមស៊ើបសួរ ដែលសរសេររៀបរាប់ប្រាប់ពីការចោទប្រកាន់ជនណាម្នាក់ ដែលបានប្រព្រឹត្តបទល្មើសនៅកន្លែងណាមួយដោយមានកាលបរិច្ឆេទ ហើយថែមទាំងប្រាប់ឈ្មោះបទល្មើស ដល់មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរ។[79]

[76] មាត្រា ១៦៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[77] មាត្រា ១៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[78] មាត្រា ១៧០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[79] មាត្រា ១៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចំពោះដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ ផ្តល់សិទ្ធិឱ្យមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការប្រើប្រាស់អំណាចធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និង ការពិនិត្យរបស់ខ្លួនដូចជា ការស្តាប់ចម្លើយរបស់សាក្សី ការឆែកឆេរ ការចាប់យកវត្ថុតាង និងការឃាត់ខ្លួនជាដើម។[80]

**ឃ. ការឃុំខ្លួនបណ្តោះអាសន្ន**

ការឃុំខ្លួនបណ្តោះអាសន្ន ជាវិធានការមួយដើម្បីរារាំង ឬ ទប់ស្កាត់មិនឱ្យពិរុទ្ធជនរត់ចេញពីការទទួលទោសនូវអំពើដែលខ្លួនបានប្រព្រឹត្តដោយខ្លាចពិរុទ្ធជនគេចខ្លួនបាត់មិនត្រឡប់មកបង្ហាញខ្លួនចំពោះមុខតុលាការ ឬខ្លាចពិរុទ្ធជននោះប្រើឥទ្ធិពលលើសាក្សី ឬ រាំងស្ទះដល់ដំណើរការស៊ើបសួររបស់ចៅក្រម ឬ ក៏ទៅប្រព្រឹត្តបទល្មើសអ្វីមួយផ្សេងទៀតមុនការបើកជំនុំជម្រះក្តី។ និយាយរួម គឺធានាដល់ដំណើរនៃការស៊ើបសួរតែម្តង ។[81]

បន្ទាប់ពីចៅក្រមសម្រេចធ្វើការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នហើយ ជនត្រូវចោទមានសិទ្ធិសុំនៅក្រៅឃុំបណ្តោះអាសន្ន ឬ ក៏អាចធ្វើតាមរយៈមេធាវីរបស់ខ្លួនបាន មានន័យថាមេធាវីត្រូវដាក់ពាក្យសុំឱ្យកូនក្តីខ្លួននៅក្រៅឃុំទៅចៅក្រមស៊ើបសួរ ដោយមានបង្ហាញនូវមធ្យោបាយការពារកូនក្តីរបស់ខ្លួន ដែលមធ្យោបាយទាំងនោះគឺសមស្រប និងមានហេតុផលគ្រប់គ្រាន់ដែលមិនអាចឱ្យជនត្រូវចោទរត់គេចខ្លួនបាន ។[82] ក្នុងរយៈពេល ៥ ថ្ងៃក្រោយពេលស្នើសុំ ចៅក្រមស៊ើបសួរត្រូវឆ្លើយតប តាមដីកាដែលមានចែងពីមូលហេតុ។ មេធាវី ឬ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ ក្នុងរយៈពេល ១ខែ បន្ទាប់ពីសេចក្តីសម្រេចបដិសេធលើកដំបូងបាន។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេច ក្នុងរយៈពេល ៥ ថ្ងៃទេ មេធាវី ឬជនត្រូវចោទ អាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរឱ្យសម្រេចជំនួស ចៅក្រមស៊ើបសួរតែម្តង ។[83]

## ១.២. តួនាទីរបស់មេធាវីអំឡុងពេលជំនុំជម្រះ

នៅក្នុងវិស័យតុលាការ "សវនាការ" គឺជាការបើកការជំនុំជម្រះរឿងក្តីណាមួយ ហើយក៏ជាឱកាសដែលចៅក្រមត្រូវសួរដេញដោលវែកញែកទទួលការដោះសាររបស់គូភាគី ព្រមទាំងការលើកឡើងរបស់មេធាវីទៀតផង ហើយការវិនិច្ឆ័យសេចក្តីដោយការចេញសាលក្រម។

ជាគោលការណ៍ សវនាការត្រូវប្រកាសជាសាធារណៈ គឺលើកលែងតែមានការស្នើសុំពីភាគីណាមួយ នៃរឿងក្តីដែលពុំអាចធ្វើជាសាធារណៈបាន ។[84]

---

[80] មាត្រា ១៨១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[81] មាត្រា ២០៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[82] មាត្រា ២០៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[83] មាត្រា ២១៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[84] មាត្រា ៣១៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលសំខាន់បំផុតសម្រាប់រឿងក្តី ហើយក៏អាចជាទីផ្តាច់ព្រាត់សម្រាប់មេធាវីក្នុងការជជែកតវ៉ារកផលប្រយោជន៍ឱ្យកូនក្តីរបស់ខ្លួន។ ឈានចូលដល់ដំណាក់កាលនេះ មេធាវីឬអ្នកការពារក្តីត្រូវទទួលបានសិទ្ធិក្នុងការជូនដំណឹងពីថ្ងៃសវនាការ ហើយតុលាការអាចប្រគល់លិខិតឱ្យមេធាវីឬលិខិតអញ្ជើញមេធាវី តាមរយៈផ្លូវប្រៃសណីយ៍ ឬផ្លូវរដ្ឋបាល ប៉ុន្តែក្នុងករណីចាំបាច់អាចធ្វើបានតាមគ្រប់មធ្យោបាយ ។[85]

មេធាវី អាចតំណាងសិទ្ធិឱ្យកូនក្តី ធ្វើពាក្យប្តឹងសុំប្តូរសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ដោយមានមូលហេតុត្រឹមត្រូវតាមច្បាប់ ក្រោមហេតុផលចៅក្រមកំពុងតែលំអៀងទៅរកភាគីណាមួយ ដោយចៅក្រមជំនុំជម្រះនោះជាសាច់ញាតិរបស់ភាគីណាមួយជាដើម។

ម្យ៉ាងទៀត ប្រសិនបើមេធាវីពិនិត្យឃើញថាគួរឲ្យមានការបើកសវនាការដោយការសម្ងាត់ មេធាវីអាចស្នើសុំភ្លាមទៅចៅក្រមដោយមានបញ្ជាក់ពីមូលហេតុផងដែរ ។[86]

### ១.២.១. បញ្ហា និង អង្គហេតុ

ក្នុងពេលសវនាការ ការលើកពីបញ្ហាជាប្រការសំខាន់មួយសម្រាប់មេធាវី ដើម្បីជាការពញ្ញាក់ដល់ចៅក្រម និង អ្នកដទៃទៀតឱ្យចាប់អារម្មណ៍ ។ តើអ្វីទៅជាបញ្ហា? ព្រោះបញ្ហា គឺជាគន្លឹះនៃរឿងក្តីទាំងមូល។

ម្យ៉ាងទៀតការក្តាប់បាននូវអង្គហេតុមានសារៈសំខាន់ណាស់ ហើយមេធាវីត្រូវដឹងថា អង្គហេតុណាល្អ និង អង្គហេតុណាអាក្រក់ មួយណាមានប្រយោជន៍ និងមួយណាគ្មានប្រយោជន៍ចំពោះកូនក្តីខ្លួន។ ការលើកពីអង្គហេតុរបស់មេធាវី ត្រូវអាស្រ័យទៅតាមករណីផ្សេងៗគ្នានៃរឿងក្តី មេធាវីជួនកាលលើកយកពីរឿងរ៉ាវដែលបានយកចេញពីអ្វីដែលមានហើយក្នុងសំណុំរឿង និងអ្វីដែលទទួលបានពីការស៊ើបអង្កេត ហើយភាគច្រើន មេធាវីលើកយកមកនិយាយតែពីអង្គហេតុល្អតែប៉ុណ្ណោះ ព្រោះវាជាហេតុដែលនាំឲ្យមានផលវិជ្ជមានក្នុងការដោះបន្ទុកចំពោះកូនក្តីរបស់ខ្លួន។ និយាយឱ្យចំ ការលើកពីអង្គហេតុ គឺការលើកពីមូលហេតុដែលបណ្តាលឱ្យកើតមានបញ្ហា ឬ វិវាទ។

[85] មាត្រា ២៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[86] មាត្រា ៣១៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ១.២.២. ការពិភាក្សាដេញដោល

សំណួររបស់មេធាវីក្នុងពេលសវនាការ គឺជាសំណួរផ្ទាល់មាត់ ក្រោយពីបានទទួលការអនុញ្ញាតពីចៅក្រមនិង ជាការសួរដេញដោលមួយ ដែលមេធាវីធ្វើទៅលើកូនក្តី និង សាក្សី ឬ ភាគីនានាក្នុងពេលសវនាការ ហើយមេធាវីអាចចាត់ទុកថា ជាការទាញយកព័ត៌មានសម្រាប់ការពិចារណា។[87]

ប៉ុន្តែមុននឹងឈានចូលដល់លក្ខណៈនៃការសួរកូនក្តី និងសាក្សី យើងត្រូវដឹងអំពីដំណើរការសាកសួរជាមុនសិន ពិសេសគឺតួនាទីនៃអ្នកចូលរួម និងមេធាវី។

ចៅក្រមជាអ្នកដឹកនាំសវនាការ [88] ហេតុនេះ ចៅក្រមជាអ្នកសួរដេញដោលលើអ្នកដែលពាក់ព័ន្ធក្នុងរឿងក្តីមុនគេ។

បន្ទាប់ពីចៅក្រម គឺតំណាងអយ្យការអមតុលាការ (ព្រះរាជអាជ្ញា) ដែលជាអ្នកមានសិទ្ធិសួរដេញដោលដោយផ្ទាល់ទៅលើអ្នកដែលមានពាក់ព័ន្ធក្នុងរឿងដូចជា ជនជាប់ចោទ សាក្សី និង ជនរងគ្រោះដែលមានវត្តមាននៅពេលសវនាការ ។

បន្ទាប់ពីតំណាងអយ្យការអមតុលាការ (ព្រះរាជអាជ្ញា) រួចមក និងក្រោយពេលបានការអនុញ្ញាតពីចៅក្រម គឺមេធាវីការពារឱ្យជនជាប់ចោទមានសិទ្ធិសួរដោយផ្ទាល់ដូចតំណាងអយ្យការដែរ។ បន្តមកទៀត គឺដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចលើកសំណួរសួរចំពោះជនជាប់ចោទ និងសាក្សីបានដោយត្រូវសួរតាមរយៈចៅក្រម ។[89]

### ១.២.៣. ការបង្ហាញភស្តុតាង[90]

- **ចំពោះមេធាវីការពារជនត្រូវចោទ**

មេធាវីចាំបាច់ត្រូវលើកបង្ហាញភស្តុតាង ដែលខ្លួនប្រមូលបានសម្រាប់ជាការដោះបន្ទុកដល់កូនក្តីរបស់ខ្លួនដាក់ជូនទៅចៅក្រម និងធ្វើការបង្ហាញដល់ចៅក្រមឱ្យបានក្បោះក្បាយ និងគ្រប់ជ្រុងជ្រោយ ។ ម្យ៉ាងទៀតមេធាវីត្រូវដឹង និងសិក្សាផងដែរពីភស្តុតាងរបស់ភាគីម្ខាងទៀតថាជាភស្តុតាងប្រភេទណា ដោយរួមជាមួយនឹងការវិភាគផងដែរពីទំនាក់ទំនងហេតុនៃភស្តុតាង និង អង្គហេតុ ថាតើវាស៊ីសង្វាក់គ្នាដែរឬទេ? បើមើលឃើញចំណុចណាមួយមិនត្រឹមត្រូវ មេធាវីត្រូវលើកយកមកបង្ហាញហើយធ្វើការសន្និដ្ឋាន និងសុំបដិសេធចោលភស្តុតាងដាក់បន្ទុកទាំងនោះ។

[87] មាត្រា ៣២៥ វាក្យខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[88] មាត្រា ៣១៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[89] មាត្រា ៣២៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[90] មាត្រា ៣៣២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- **ចំពោះមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

មេធាវីចាំបាច់ត្រូវដឹង និងសិក្សាពីភស្តុតាងនានាដែលខ្លួនប្រមូលបានកំឡុងពេលស៊ើបអង្កេតរបស់ខ្លួនដើម្បីយកមកដាក់បង្ហាញជូនចៅក្រម និងដាក់បន្ទុកទៅលើជនជាប់ចោទ។ ម្យ៉ាងទៀត មេធាវីត្រូវពិនិត្យមើលលើភស្តុតាងដោះបន្ទុករបស់ជនជាប់ចោទដែលដាក់បង្ហាញ និងធ្វើការតវ៉ាភ្លាមៗនៅពេលដែលខ្លួនពិនិត្យមើលទៅឃើញថាភស្តុតាងទាំងនោះ កើតមានឡើងមិនទាក់ទងទៅនឹងអង្គហេតុ ដោយធ្វើការសន្និដ្ឋាន និងសុំបដិសេធចោលនូវភស្តុតាងដោះបន្ទុកទាំងនោះ។

### ១.២.៤. ពេលសន្និដ្ឋានការពារ

រហូតមកទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និង ជូនលិខិតស្នាមទាំងអស់ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស្វែងឱ្យឃើញការពិត ។[91]

ក្នុងដំណាក់កាលនៃការធ្វើសេចក្ដីសន្និដ្ឋានការពារ គឺមេធាវីការពារមានកាតព្វកិច្ចធ្វើសេចក្ដីសន្និដ្ឋានជំនួសឱ្យកូនក្ដីរបស់ខ្លួន ដើម្បីបង្ហាញនូវសំណូមពរ និង ការយល់ឃើញរបស់មេធាវី នៅដំណាក់កាលចុងក្រោយនៃដំណើរការសវនាការកាត់ក្ដី និង ដើម្បីការពារផលប្រយោជន៍ និងសិទ្ធិស្របច្បាប់របស់កូនក្ដីខ្លួន ។

ដើម្បីឱ្យសេចក្ដីសន្និដ្ឋានការពាររបស់មេធាវី ទទួលបានជោគជ័យ គឺ[92] ៖

- **ករណីយកិច្ចរបស់មេធាវីក្នុងពេលការពារក្ដី**

នៅពេលធ្វើការសន្និដ្ឋានការពារ មេធាវីត្រូវលើកឡើងបង្ហាញចៅក្រមពីទ្រឹស្ដីការពារ ដោយផ្អែកតាមអង្គហេតុ (ដំណើរដើមទងនៃរឿងក្ដី) ដោយបង្ហាញពីអង្គច្បាប់ និង ភស្តុតាងនានាព្រមទាំងសាក្សីទាំងឡាយនៅចំពោះមុខអង្គសវនាការ។ មេធាវីត្រូវធ្វើឱ្យចៅក្រមដឹងថា សាក្សី ឬ ភស្តុតាងរបស់ភាគីម្ខាងទៀត ជាសាក្សីគ្មានតម្លៃ ឬ ភស្តុតាងមិនអាចយកជាការបាន។ ចំណែកឯសាក្សី ឬ ភស្តុតាងខាងខ្លួនវិញ មេធាវីត្រូវលើកបង្ហាញ និងពន្យល់បកស្រាយបន្ថែម ដើម្បីឱ្យចៅក្រមយល់ស្របតាមដោយឈរលើមូលដ្ឋានសមហេតុផល ។

- **ការឆ្លើយតប និង ការដោះសារ**

ជួនកាល ក្រោយពេលស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីភាគីម្ខាង ទើបមេធាវីរកឃើញចំណុចចោទប្រកាន់សំខាន់ផ្សេងៗទៀត ដូច្នេះមេធាវីត្រូវធ្វើការឆ្លើយតប និង ដោះសារលើគ្រប់ចំណុចទាំងនោះកុំឱ្យចៅក្រមយល់ច្រឡំថា មេធាវីយល់ព្រមតាមភាគីបដិបក្ខដោយគ្មានការតវ៉ា ឬគ្មានប្រតិកម្មអ្វីឡើយ។

- **សំណូមពរ**

[91] មាត្រា ៣៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[92] មាត្រា ៣៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មេធាវីមិនត្រូវខកខាននឹងការធ្វើសំណូមពរនេះឡើយ។ មេធាវីត្រូវស្នើសុំទៅចៅក្រម តាមតម្រូវការរបស់កូនក្តីខ្លួន។

## ១.៣. តួនាទីមេធាវី ក្រោយបញ្ចប់ពេលជំនុំជម្រះ

មេធាវីត្រូវពន្យល់ពីអត្ថន័យ នៃសាលក្រមដែលបានចេញដោយតុលាការនោះឱ្យកូនក្តីរបស់ខ្លួនបានយល់ច្បាស់ ដើម្បីកូនក្តីខ្លួនយល់ត្រឹមត្រូវពីអត្ថន័យនៃការសម្រេចរបស់តុលាការចំពោះរឿងក្តី ក្នុងករណីដែលកូនក្តីរបស់ខ្លួនពុំយល់ស្របនឹងសេចក្តីសម្រេចរបស់តុលាការទេ មេធាវីក៏ត្រូវតែធ្វើការពន្យល់ណែនាំកូនក្តីរបស់ខ្លួនផងដែរទាក់ទងនឹងលទ្ធភាពនៃសិទ្ធិលើការធ្វើបណ្តឹងទៅតុលាការជាន់ខ្ពស់ផងដែរ។

### ក. បណ្តឹងទៅតុលាការជាន់ខ្ពស់

បណ្តឹងទៅតុលារការជាន់ខ្ពស់ គឺជាវិធីដែលភាគីអាចប្តឹងសុំផ្ទេររឿងក្តីដែលបានសម្រេចនៅសាលាដំបូង ហើយភាគីមិនយល់ស្របទៅនឹងលទ្ធផលនៃសេចក្តីសម្រេចនោះ។ មួយវិញទៀត បណ្តឹងទៅតុលាការជាន់ខ្ពស់រួមមាន បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខ និងបណ្តឹងសើរើ។

### ក.១.បណ្តឹងទាស់

បណ្តឹងទាស់ គឺជាបណ្តឹងដែលពិរុទ្ធជនអាចប្តឹងទាស់និងសាលដីកាដែលសម្រេចដោយកំបាំងមុខដែលធ្វើឡើងដើម្បីឲ្យតុលាការដែលបានសម្រេចសេចក្តីរួចហើយមកជម្រះសេចក្តីឡើងវិញម្តងទៀត។[93] បណ្តឹងទាស់ មានរយៈពេល ១៥ថ្ងៃ បន្ទាប់ពីទទួលបានសាលក្រម ឬសាលដីកា ។[94] អានុភាព កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសាលក្រមទាំងមូល សាលក្រមនេះត្រូវទុកជាអសារបង់។ ការអនុវត្តសាលក្រមត្រូវព្យួរ ។ប៉ុន្តែដីកាបង្គាប់ឱ្យ ចាប់ខ្លួននៅតែមានអានុភាព ។ តុលាការនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចអំពីការដោះលែងជនជាប់ចោទឱ្យ មានសេរីភាពវិញ។ កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី មានតែសេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះ ដែលត្រូវទុកជាអសារបង់ ។រីឯ ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនេះត្រូវព្យួរ ។[95] ម្យ៉ាងវិញទៀត របៀបនៃការប្តឹងបណ្តឹងទាស់អាចធ្វើឡើងបានតាមរយៈការដាក់ពាក្យបណ្តឹងសរសេរជាលាយលក្ខណ៍អក្សរដាក់នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ឬ សាលដីកា នៅចំពោះមុខព្រះរាជអាជ្ញា ឬអង្គភាពនគរបាលឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[96]

[93] មាត្រា ៣៦២ និងមាត្រា ៤០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[94] មាត្រា ៣៦៨ និងមាត្រា ៤១២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[95] មាត្រា ៣៧០ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[96] មាត្រា ៣៦៦ និងមាត្រា ៤១០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

## ក.២.បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងដែលធ្វើឡើងនៅពេលដែលព្រះរាជអាជ្ញា ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬ តំណាងស្របច្បាប់មិនសុខចិត្តចំពោះសាលក្រមដែលបានសម្រេចសេចក្តី ហើយមានអានុភាពផ្ទេរបណ្តឹងដែលបានជំនុំជម្រះនៅសាលាដំបូងយកទៅជំនុំជម្រះនៅឯសាលាឧទ្ធរណ៍វិញម្តង។[97]បណ្តឹងឧទ្ធរណ៍មានរយៈពេល ១ខែ សម្រាប់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ហើយមានរយៈពេល ៣ខែ សម្រាប់អគ្គព្រះរាជអាជ្ញា ។ របៀបប្តឹងបណ្តឹងរបស់ព្រះរាជាអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។[98] ចំណែកឯការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ។[99]

## ក.៣.បណ្តឹងសារទុក្ខ

បណ្តឹងសារទុក្ខ គឺជាបណ្តឹងដែលធ្វើឡើងនៅពេលដែលអគ្គព្រះរាជអាជ្ញាជនជាប់ចោទដើមបណ្តឹងរដ្ឋប្បវេណី ឬតំណាងស្របច្បាប់មិនសុខចិត្តចំពោះសាលដីការបស់សាលាឧទ្ធរណ៍។[100] រយៈពេល ១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ១៥ (ដប់ប្រាំ) ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ៥ (ប្រាំ) ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន។

ចំណែកឯរបៀបប្តឹង របៀបប្តឹងបណ្តឹងសារទុក្ខ ត្រូវធ្វើតាមពាក្យប្តឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានចេញសេចក្តីសម្រេច។ ពាក្យប្តឹងនេះត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ។[101]

## ក.៤.បណ្តឹងសើរើ

បណ្តឹងសើរើ គឺជាបណ្តឹងតវ៉ាមួយប្រឆាំងទៅនឹងសាលក្រមឬសាលដីកាដែលបានចូលជាស្ថាពរ ហើយដែលមានអាជ្ញាអស់ជំនុំ។[102] ហើយមានរយៈពេល ៣០ថ្ងៃ ឬមានលក្ខណៈពិសេសរយៈពេលនេះអាចពន្យាបានដោយប្រធានតុលាការកំពូល[103]។

---

[97] មាត្រា ៣៨១និងមាត្រា ៣៨២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[98] មាត្រា ៣៧៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[99] មាត្រា ៣៧៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[100] មាត្រា ៤១៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[101] មាត្រា ៤២២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[102] មាត្រា ៤៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[103] មាត្រា ៤៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

## ២. តួនាទីក្នុងរឿងក្តីរដ្ឋប្បវេណី

ជាទូទៅតួនាទីមេធាវីក្នុងរឿងក្ដីរដ្ឋប្បវេណីគឺធ្វើការតាមភារកិច្ចរបស់ខ្លួនផ្អែកទៅលើការទាមទារតាមផ្លូវបណ្តឹងដែលបានចែកជាបីប្រភេទទៅតាមខ្លឹមសារបណ្តឹងដូចជា៖ បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក បណ្តឹងទាមទារឱ្យបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងបណ្តឹងទាមទារឱ្យបង្កើត ឬរំលត់នូវទំនាក់ទំនងគតិយុត្តិ។[104] ប៉ុន្តែ ក្រៅពីការទាមទារតាមផ្លូវបណ្តឹង ច្បាប់ក៏បានកំណត់ពីនីតិវិធីដោយឡែកផងដែរ គឺនីតិវិធីដាស់តឿនក្នុងករណីដែលកូនបំណុលទទួលស្គាល់នូវកាតព្វកិច្ចរបស់ខ្លួន លើកលែងតែមានការតវ៉ាពីកូនបំណុលទើបត្រូវផ្ទេរទៅនីតិវិធីបណ្តឹងវិញ ដោយការកំណត់នេះគឺផ្តល់លទ្ធភាពដល់រឿងក្តីពុំចាំបាច់ចំណាយពេលយូរនោះឡើយ។[105]

ជាការពិតណាស់ នៅពេលមានបណ្តឹងរដ្ឋប្បវេណីកើតឡើង គូភាគីតែងតែចង់ឈ្នះរៀងខ្លួន ដូចនេះគេត្រូវការអ្នកតំណាងដោយអាណត្តិដើម្បីជួយផ្តល់យោបល់ និងមធ្យោបាយផ្លូវច្បាប់ដែលឆ្លើយតបទៅនឹងបញ្ហាដ៏មានប្រសិទ្ធិភាពសម្រាប់ពួកគេ។

### ២.១.តួនាទីរបស់មេធាវី មុនពេលជំនុំជម្រះ

ការជំនុំជម្រះក្នុងរឿងក្តីរដ្ឋប្បវេណី អាចប្រព្រឹត្តទៅបានលុះត្រាតែមានការដាក់ពាក្យបណ្តឹងពីដើមចោទដើម្បីសុំឱ្យតុលាការអន្តរាគមន៍លើចំណុចវិវាទរបស់ពួកគេ។ យ៉ាងណាមិញ នៅមុនពេលដាក់ពាក្យបណ្តឹងក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីស្វែងរកដំណោះស្រាយចំពោះការការពារផលប្រយោជន៍របស់ពួកគេ យើងសង្កេតឃើញថាមេធាវីគឺមានតួនាទីសំខាន់នៅមុនពេលបណ្តឹងកើតឡើង គឺមេធាវីត្រូវពិគ្រោះនិងផ្តល់យោបល់ផ្នែកច្បាប់ដល់អតិថិជន ដែលការពិគ្រោះផ្នែកច្បាប់នេះគឺអាចធ្វើនៅការិយាល័យដើម ឬក្នុងការិយាល័យសាខារបស់ខ្លួន ឬនៅទីកន្លែងផ្សេងទៀតដែលមានភាពសមរម្យ និងធានាបាននូវការសម្ងាត់វិជ្ជាជីវៈ ។[106] ម្យ៉ាងវិញទៀត នៅគ្រប់ប្រភេទរឿងក្តីរួមទាំងរឿងរដ្ឋប្បវេណី ឬរឿងក្តីព្រហ្មទណ្ឌ មេធាវីអាចអនុវត្តភារកិច្ច និងទទួលបាននូវសិទ្ធិតំណាងឱ្យកូនក្តីរបស់ខ្លួនបាន លុះត្រាតែមានលិខិតប្រគល់សិទ្ធិ ឬលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ឬលិខិតដែលបញ្ជាក់ពីការព្រមព្រៀងជាមួយអតិថិជនរបស់ខ្លួន ហើយក្នុងលិខិតនោះត្រូវសរសេរលំអិតអំពីសិទ្ធិ និងតួនាទីរបស់មេធាវីដែលអតិថិជនបានប្រគល់សិទ្ធិស្របតាមច្បាប់ ដែលលិខិតគំរូមានកំណត់ដោយគណៈមេធាវី ។[107]

---

[104] មាត្រា ៧៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[105] មាត្រា ៣១៩ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[106] មាត្រា ១៣ ក្រមសីលធម៌មេធាវីនៃគណៈមេធាវី ឆ្នាំ២០១២

[107] មាត្រា ២៣ ក្រមសីលធម៌មេធាវីនៃគណៈមេធាវី ឆ្នាំ២០១២

មួយវិញទៀត នៅពេលដែលភាគីជម្លោះមានបំណងប្ដឹងទៅតុលាការ មេធាវីត្រូវសរសេរពាក្យបណ្ដឹងឱ្យបានក្បោះក្បាយច្បាស់លាស់ និងស្របតាមឆន្ទៈរបស់កូនក្ដីរបស់ខ្លួនដើម្បីដាក់ជូនទៅតុលាការឱ្យធ្វើការជំនុំជម្រះ និងចេញសាលក្រមចំពោះការទាមទាររបស់ពួកគេ។ រីឯ ការសរសេរនូវពាក្យបណ្ដឹងសម្រាប់អតិថិជនដើម្បីដាក់ទៅតុលាការដែលនៅក្នុងលិខិតនៃពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់នូវចំណុចដូចជា៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។
- សរសេរបញ្ជាក់ឱ្យបានច្បាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារនិង តាមចំណុចដែលត្រូវការបញ្ជាក់ដោយភស្តុតាង។
- សរសេរពីមធ្យោបាយតទល់ ឬការពារខ្លួន សម្រាប់ជាឯកសារត្រៀមផងដែរ ។[108]

## ២.១.១ តួនាទីរបស់មេធាវី ក្នុងនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺជានីតិវិធីដែលធ្វើឡើងមុនពេលនីតិវិធីទាញហេតុផលផ្ទាល់មាត់ ពីព្រោះអាចផ្ដល់ជាមូលដ្ឋានសម្រាប់ការវិនិច្ឆ័យជម្រះក្ដីនៅក្នុងការទាញហេតុផលផ្ទាល់មាត់ឱ្យបានល្អិតល្អន់ និងការបំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីមិនស្របគ្នា និងរៀបចំដាក់ភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដី ។[109] សម្រាប់នីតិវិធីនេះ តុលាការត្រូវកំណត់កាលបរិច្ឆេទលើកដំបូងក្នុងអំឡុងពេល ៣០ថ្ងៃបន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់ ។[110]

ស្របគ្នានេះដែរ នៅក្នុងនីតិវិធីត្រៀមសម្រាបការទាញហេតុផលនេះគឺមេធាវីអាចតំណាងឱ្យកូនក្ដីដើម្បីការពារផលប្រយោជន៍កូនក្ដីរបស់ខ្លួនបាន និងនៅគ្រប់ដំណាក់កាលនីមួយៗនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ដែលនីតិវិធីទាំងនោះរួមមានដូចជា ការរៀបចំដាក់ឯកសារត្រៀម ការសាកល្បងផ្សះផ្សា ការធ្វើសេចក្ដីថ្លែងការណ៍ ការបំភ្លឺចំណុចវិវាទ និងការស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង ។[111]

---

[108] មាត្រា ៧៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[109] មាត្រា ១០៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[110] មាត្រា ៨០ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[111] មាត្រា ១០៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### ក. តួនាទីរៀបចំដាក់ឯកសារត្រៀម

នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម ដែលនៅក្នុងឯកសារត្រៀននោះត្រូវសរសេរអំពីមធ្យោ បាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត។[112] ត្រង់ចំណុចនេះ មេធាវីដែលជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទត្រូវរៀបចំ និងបញ្ជាក់ឱ្យបានច្បាស់លាស់ពីការទាមទារដែលកូនក្តីរបស់ខ្លួនចង់បាន ជាពិសេសត្រូវសរសេរអង្គហេតុសំខាន់ៗដែលទាក់ទងនឹងមូលហេតុនៃការទាមទារ និងការផ្តល់នូវភស្តុតាងផងដែរ ។ ចំណែកឯ មេធាវីតំណាងឱ្យចុងចម្លើយត្រូវសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានទាមទារនៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលមានបញ្ជាក់ក្នុងពាក្យបណ្តឹង និងអង្គហេតុតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹងជាអាទិ៍ ។[113]

### ខ. តួនាទីផ្សះផ្សាដោយមេធាវី

នៅក្នុងនីតិវិធីត្រៀមទាញហេតុផល តុលាការត្រូវតែធ្វើការសាកតែធ្វើការសាកល្បងផ្សះផ្សាជាមុនសិន លើកលែងតែក្នុងករណីដែលយល់ថាមិនសមរម្យ។ ការផ្សះផ្សាដែលធ្វើឡើងក្នុងនីតិវិធីនេះ គឺអាចធ្វើឡើងដោយពីរដំណាក់កាល ដោយលើកដំបូងគឺជាការផ្សះផ្សាដោយមេធាវី និងលើកទីពីរគឺធ្វើឡើងដោយតុលាការ។ ពោលមេធាវីគឺមានតួនាទីសំខាន់ទាំងក្នុងការផ្សះផ្សាដែលធ្វើឡើងដោយមេធាវី និងធ្វើឡើងដោយតុលាការ។ ក្នុងន័យនេះ មេធាវីដែលតំណាងឱ្យកូនក្តីនៃភាគីម្ខាងទៀតអាចសាកល្បងធ្វើការផ្សះផ្សា សម្របសម្រួលជាមួយភាគីម្ខាងទៀត ប្រសិនបើមានការឯកភាពពីកូនក្តីរបស់ខ្លួន ។[114]

មេធាវីត្រូវពិគ្រោះយោបល់ ហើយសម្រុះសម្រួលភាគីដោយពន្យល់ណែនាំផលវិជ្ជមាន និងការចំណេញពេលវេលា ក៏ដូចជាប្រាក់កាស កាលបើពួកគេធ្វើការដោះស្រាយតាមផ្លូវក្រៅតុលាការ។ ម្យ៉ាងវិញទៀតមេធាវីក៏អាចធ្វើការណាត់ជួបជាមួយភាគីទាំងសងខាងដើម្បីពិភាក្សា ជជែកទល់មុខផ្ទាល់ ដើម្បីរកដំណោះស្រាយដ៏សមស្របមួយដែលគូភាគីទាំងសងខាងអាចទទួលយកបាន និងរក្សាបានផលប្រយោជន៍នៃភាគីទាំងពីរ។ មិនត្រឹមតែប៉ុណ្ណោះ ការដោះស្រាយវិវាទតាមផ្លូវក្រៅតុលាការក៏ជាមូលហេតុដែលលើកកម្ពស់ដល់ការគោលនយោបាយនៃការដោះស្រាយការកកស្ទះសំណុំរឿងក្នុងតុលាការផងដែរ។

[112] មាត្រា ១០១ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[113] មាត្រា ១០១ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[114] មាត្រា ១០៤ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### គ. តួនាទីក្នុងការធ្វើសេចក្តីថ្លែងការណ៍

សេចក្តីថ្លែងការណ៍ គឺសំដៅលើការថ្លែងដោយផ្ទាល់មាត់របស់ភាគីបណ្តឹងចំពោះមុខតុលាការក្នុងការទាមទារ ការលើកអង្គហេតុ និងអង្គច្បាប់សំខាន់ៗដែលបញ្ជាក់ពីការទាមទារ មូលហេតុនៃការទាមទារ (ចំពោះមេធាវីដើមចោទ) និងបកស្រាយអំពីខ្លឹមសារ និងអង្គហេតុការពារខ្លួនដែលឆ្លើយតបទៅនឹងការទាមទាររបស់ដើមចោទ(ចំពោះមេធាវីចុងចម្លើយ)។[115]

ត្រង់ចំណុចនេះ មានន័យថានៅក្នុងនីតិវិធីត្រៀមទាញហេតុផលដដែល បន្ទាប់ពីភាគីបានរៀបចំនូវការអះអាង និងភស្តុតាងរួចមក ដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួគឺ វិធីតទល់ រីឯចុងចម្លើយនឹងត្រូវធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួនដែរគឺ វិធីការពារខ្លួន។

មួយវិញទៀត មេធាវីទាំងសងខាងត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួននោះទៅតាមពេលសមរម្យនៃដំណាក់កាលនៃរឿងក្តី ។[116]

### ឃ. តួនាទីក្នុងការបំភ្លឺចំណុចវិវាទ

នៅពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់នូវការរៀបចំណុចវិវាទ និងភស្តុតាងរួចហើយនោះ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាងអំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់តាមរយៈការពិនិត្យភស្តុតាងនៅមុនពេលចូលដល់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ។[117] ករណីមួយនេះ មានន័យថាតុលាការ និងភាគីទាំងសងខាងត្រូវធ្វើការបញ្ជាក់ថាតើអង្គហេតុណាខ្លះដែលជាចំណុចវិវាទ ហើយដែលត្រូវជាកម្មវត្ថុនៃការពិនិត្យភស្តុតាង ដែលតុលាការ និងភាគីសងខាងត្រូវទទួលស្គាល់រួមគ្នាចំពោះចំណុចទាំងនោះ ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធីនៅពេលទាញហេតុផលផ្ទាល់មាត់ ។[118]

### ង. តួនាទីស្នើសុំតុលាការក្នុងការពិនិត្យភស្តុតាង

មេធាវីមានតួនាទីសំខាន់ក្នុងការស្វែងរកភស្តុតាងដែលផ្តល់អត្ថប្រយោជន៍ជូន កូនក្តីរបស់ខ្លួន ហើយរក្សាទុកភស្តុតាងនោះឱ្យបានល្អកុំឱ្យមានការខូចខាត ឬបាត់បង់ ដើម្បីដាក់ជូនតុលាការក្នុងការការពារអំណះអំណាងតទល់ ឬអំណះអំណាងការពារខ្លួនជាដើម។

---

[115] មាត្រា ៧៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[116] មាត្រា ៩០ និងមាត្រា ១០១ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[117] មាត្រា ១០៧ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[118] មាត្រា ១២៧ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ម្យ៉ាងវិញទៀត មេធាវីក៏ត្រូវពិនិត្យមើលភស្តុតាងដែលខ្លួនមានឱ្យច្បាស់លាស់ជាក់លាក់អំពីអង្គហេតុ និងទំនាក់ទំនាក់ទំនងអង្គហេតុនោះផងដែរ នៅមុនពេលដាក់ជូនតុលាការ ឬភាគីម្ខាងទៀត ដើម្បីធានាថាភស្តុតាងដែលខ្លួនមាននោះគឺជាភស្តុតាងដែលពិតជាត្រឹមត្រូវ ជៀសវាងពីការដាក់ភស្តុតាងក្លែងក្លាយដែលមិនអាចយកជាការបាន ហើយធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន ។[119] ចំណែកឯ អំឡុងពេលនៃការស្នើសុំឱ្យពិនិត្យភស្តុតាង គឺអាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬមុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ក៏បានដែរ ។[120]

លើសពីនេះ មេធាវីក៏អាចស្នើសុំទៅតុលាការឱ្យពិនិត្យ និងស្នើសុំឱ្យធ្វើកោសល្យវិច្ច័យដោយអ្នកជំនាញ ឬស្ថាប័នផ្សេងដែលពាក់ព័ន្ធទៅលើភស្តុតាងរបស់ភាគីម្ខាងទៀតដែលបានដាក់មកផងដែរ ប្រសិនបើមេធាវីសង្កេតឃើញថាមានបញ្ហា ឬភាពមិនប្រក្រតីណាមួយនៃភស្តុតាងនោះ ។[121]

## ២.២. តួនាទីរបស់មេធាវី អំឡុងពេលជំនុំជម្រះ

### ២.២.១ តួនាទីរបស់មេធាវី ក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់

នីតិវិធីទាញហេតុផលផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តីរបស់តុលាការដែលក្នុងសកម្មភាពរបស់តុលាការនិង សកម្មភាពរបស់ភាគីចំពោះការជម្រះក្តី ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងការស្តាប់សេចក្តីថ្លែងការណ៍នោះនៅសាលសវនការដោយបើកចំហរជាសាធារណៈ ។[122]

ដំណាក់កាលទាញហេតុផលផ្ទាល់មាត់ គឺមានគោលបំណងធានាឱ្យបាននូវគោលការណ៍ចំពោះមុខដែលផ្តល់ឱកាសដល់ភាគីសងខាងអាចធ្វើសេចក្តីថ្លែងការណ៍អំពីការអះអាងរបស់ខ្លួនដោយយុត្តិធម៌ និងស្មើភាពគ្នា ហើយក៏ដូចជាការផ្តល់ឱកាសឱ្យភាគីធ្វើការតវ៉ាចំពោះការអះអាងរបស់ភាគីម្ខាងទៀតផងដែរ ។[123]

នៅក្នុងដំណាក់កាលនេះ មេធាវីមានតួនាទីសំខាន់ៗផ្សេងៗដូចជា ការសាកល្បងផ្សះផ្សា ការធ្វើសេចក្តីថ្លែងការណ៍ ការអះអាងបន្ថែម ឬការដាក់មធ្យោបាយតទល់ ឬការពារជាថ្មី នៅពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់។

---

119 មាត្រា ១២៥ កថាខណ្ឌទី១ និងទី២ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

120 មាត្រា ១២៥ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

121 មាត្រា ១៤៤ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

122 មាត្រា ១១៥ វាក្យខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

123 មាត្រា ១១៣ និងមាត្រា១១៥ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### គ.តួនាទីផ្សះផ្សាដោយមេធាវី

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ តុលាការអាចធ្វើការសាកល្បងផ្សះផ្សាភាគីសារជាថ្មីម្តងទៀតបាន បើទោះបីជាតុលាការធ្លាប់បានធ្វើការផ្សះផ្សានេះ តែមិនត្រូវបានសះជានឹងគ្នានៅឯនីតិវិធីត្រៀមទាញហេតុផលក៏ដោយ។

នៅដំណាក់កាលនេះ មេធាវីដែលតំណាងឱ្យកូនក្តីនៃភាគីនីមួយៗត្រូវចូលរួមក្នុងដំណើរការផ្សះផ្សានេះ ដើម្បីឱ្យការផ្សះផ្សានេះធ្វើទៅបានរលូន និងការពារដល់ផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន។ មេធាវីអាចទាក់ទងទៅកាន់មេធាវីរបស់ភាគីម្ខាងទៀតដើម្បីពិភាក្សាសម្របសម្រួល រកដំណោះស្រាយដើម្បីអាចឈានដល់ការសះជានឹងគ្នាដោយការពារបានផលប្រយោជន៍សមស្របនៃភាគីទាំងសងខាង។[124]

### ខ.តួនាទីធ្វើសេចក្តីថ្លែងការណ៍ដោយមេធាវី

- ការលើកបង្ហាញនូវអង្គហេតុ

មេធាវីត្រូវលើកឡើងនូវអង្គហេតុ តាមរយៈសេចក្តីថ្លែងការណ៍ដែលមានប្រយោជន៍ដល់កូនក្តី។ លើសពីនេះទៀត មេធាវីត្រូវបង្ហាញពីភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុក ដូចជាសាក្សី ឬភស្តុតាងជាឯកសារដែលជាប្រយោជន៍ផ្សេងទៀតចំពោះកូនក្តីរបស់ខ្លួន។[125]

- ការលើកបង្ហាញនូវអង្គច្បាប់

មេធាវីត្រូវផ្ទៀងផ្ទាត់សំណួរនៃអង្គច្បាប់ ថាតើច្បាប់ណាដែលត្រូវយកមកប្រើ ដើម្បីដោះស្រាយជាមួយនឹងអង្គហេតុ។ មេធាវីនឹងធ្វើការពាររឿងក្តី តាមរយៈការលើកឡើងនូវមាត្រាច្បាប់ ដើម្បីឆ្លើយតបនឹងអង្គហេតុក្នុងអំឡុងពេលដំណើរការជំនុំជម្រះក្តី។[126]

### គ.ការដាក់មធ្យោបាយ ត ទល់ ឬការពារខ្លួនជាថ្មី

មធ្យោបាយតទល់ ឬការពារខ្លួនជាថ្មី គឺសំដៅដល់មធ្យោបាយតទល់ ឬការពារដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ ត្រង់ចំណុចនេះ ភាគីអាចដាក់មធ្យោបាយនេះនៅនីតិវិធីជំនុំជម្រះតែម្តងបាន ក្នុងករណីដែលភាគីពុំអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅឯដំណាក់កាលត្រៀមទាញហេតុផលដោយមិនមែនបណ្តាលមកពីកំហុសធ្ងន់ធ្ងរឡើយ ។[127] មួយវិញទៀត ក្នុងករណីដែលភាគីអាចដាក់

[124] មាត្រា ១៨ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២ និងមាត្រា ២២០ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[125] មាត្រា ១០១ និងមាត្រា ១១៦ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[126] មាត្រា ១០១ និងមាត្រា ១១៦ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[127] មាត្រា ៩៤ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

មធ្យោបាយតទល់ ឬការពារខ្លួនថ្មីបាន ភាគីត្រូវតែដាក់មធ្យោយបាយនោះនៅពេលសមរម្យ ក្នុងពេលធ្វើការទាញហេតុផលផ្ទាល់មាត់ បើពុំនោះទេតុលាការអាចធ្វើការលើកចោលមធ្យោបាយនោះបាន ។[128]

ម្យ៉ាងវិញទៀត មេធាវីក៏អាចស្នើឱ្យតុលាការធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី ដែលត្រូវសាកសួរលើសាក្សី [129] ឬធ្វើការសាកសួរលើសាមីភាគី [130] ដើម្បីបំភ្លឺនូវអង្គហេតុដែលជាប្រយោជន៍នៃកូនក្តីរបស់ខ្លួន។[131] លើសពីនេះទៀត មេធាវីអាចស្នើឱ្យតុលាការធ្វើកោសល្យវិច័យបានផងដែរ ដោយភ្ជាប់មកជាមួយនឹងឯកសារដែលពាក់ព័ន្ធដែលចង់ធ្វើកោសលវិច័យនោះ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ និងពិតប្រាកដនៃភស្តុតាងដែលបានដាក់ដោយភាគីម្ខាងទៀតនោះ ។[132] ប៉ុន្តែប្រសិនបើតុលាការនៅមិនទាន់មានការជឿជាក់លើភស្តុតាងរបស់ភាគីសងខាងទេ ឬក៏ការសួរដេញដោយលនៅមិនទាន់ចប់សព្វគ្រប់ទេនោះ តុលាការអាចធ្វើការទាញហេតុផលនេះឡើងវិញជាច្រើនដងរហូតដល់តុលាការមានការជឿជាក់ទៅលើភស្តុតាង និងចម្លើយនៃការសួរដេញដោលទាំងនោះ។

### ២.២.២. តួនាទីនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

#### ក.តួនាទីរបស់មេធាវី ក្នុងការធ្វើសេចក្តីសន្និដ្ឋាន

មុនពេលចៅក្រមសម្រេចសេចក្តី មេធាវីត្រូវធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីដែលមេធាវីនឹងត្រូវស្នើទៅតុលាការ ដូចជាសុំឱ្យមានសំណងជំងឺចិត្ត និងអាចធ្វើការបដិសេធពាក្យបណ្តឹងរបស់ដើមចោទជាដើម។

### ២.៣. តួនាទីរបស់មេធាវី ក្រោយបញ្ចប់ពេលជំនុំជម្រះ

នៅក្រោយពេលដែលតុលាការបានចេញសាលក្រមហើយ មេធាវីគឺនៅតែមានតួនាទីសំខាន់ក្នុងការជួយពន្យល់ និងណែនាំពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យ និងសិទ្ធិធ្វើបណ្តឹងសុំអនុវត្តសាលក្រមដល់កូនក្តីរបស់ខ្លួន។

### ២.៣.១. តួនាទីក្នុងការពន្យល់ពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យដល់កូនក្តី

មេធាវីត្រូវពន្យល់ពីអត្ថន័យ នៃសាលក្រមដែលបានចេញដោយតុលាការនោះឱ្យកូនក្តីរបស់ខ្លួនបានយល់ច្បាស់ ដើម្បីកូនក្តីខ្លួនយល់ត្រឹមត្រូវពីអត្ថន័យនៃការសម្រេចរបស់តុលាការចំពោះរឿងក្តី ក្នុងករណីដែលកូនក្តីរបស់ខ្លួនពុំយល់ស្របនឹងសេចក្តីសម្រេចរបស់តុលាការទេ មេធាវីក៏ត្រូវតែធ្វើការពន្យល់ណែនាំកូនក្តីរបស់ខ្លួនផងដែរទាក់ទងនឹងលទ្ធភាពនៃសិទ្ធិលើការធ្វើបណ្តឹងឧបាស្រ័យផងដែរ។

[128] មាត្រា ៩៣ និងមាត្រា ៩៤ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[129] មាត្រា ១៣៨ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[130] មាត្រា ១៣៩ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[131] មាត្រា ៩០ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[132] មាត្រា ១៤៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### គ. បណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យ គឺជាវិធីធ្វើប្តឹងតវ៉ាដោយភាគី ឬតតិយជន ទៅសាលាដំបូងដែលបានចេញសាលក្រមដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេច ហើយបណ្តឹងឧបាស្រ័យធម្មតានោះ រួមមានបណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខ បណ្តឹងទាស់ បណ្តឹងជំទាស់ និងបណ្តឹងតវ៉ា។

### គ.១. បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាវិធីប្តឹងចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូង។ រីឯ ពាក្យបណ្តឹងឧទ្ធរណ៍មានអានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រមសាលដំបូង ។[133] មានន័យថា មានអានុភាពផ្ទេរការជម្រះក្តីពីសាលាដំបូងទៅសាលាឧទ្ធរណ៍។ អំឡុងពេលប្តឹងឧទ្ធរណ៍ ១ខែ គិតពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ២សប្តាហ៍ គិតពីថ្ងៃដែលចេញដីកាសម្រេចច្រានចោល ឬលើកចោលបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។ ប៉ុន្តែមេធាវីតំណាងសិទ្ធិឱ្យភាគីអាចពន្យាអំឡុងពេលសម្រាប់បណ្តឹងឧទ្ធរណ៍នេះបាន ដោយមានមូលហេតុសមស្រប ឬតាមបញ្ញត្តិច្បាប់ដោយលិខិតជាលាយល័ក្ខណ៍អក្សរ ឬផ្ទាល់មាត់កាលបើពុំអាចជៀសវាងបាន។ ដោយអំឡុងពេលគិតរាប់ក្រោយពីមូលហេតុត្រូវបានបញ្ចប់ ១សប្តាហ៍ នៅក្នុងប្រទេស និង ២ ខែ ចំពោះភាគីដែលនៅបរទេស ។[134]

### គ.២. បណ្តឹងសារទុក្ខ

បណ្តឹងសារទុក គឺជាវិធីប្តឹងចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ឬអាចប្តឹងចំពោះសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី១ ក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍នៅក្រោយពេលដែលតុលាការបានចេញសាលក្រមនោះ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខតែម្តង។ អានុភាពនៃបណ្តឹងសាទុក្ខ មានគោលបំណងឱ្យតុលាការកំពូលពិនិត្យ វិនិច្ឆ័យ តែទៅលើអង្គច្បាប់តែប៉ុនណ្ណោះថា តើអង្គច្បាប់ដែលតុលាការថ្នាក់ក្រោមសម្រេចយកមកប្រើ មានភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តនានាដែលមានជាធរមានដែរ ឬទេ។ ចំណែកឯ អំឡុងពេលប្តឹងសាទុក្ខគឺ ១ខែ គិតពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ២សប្តាហ៍ គិតពីថ្ងៃដែលចេញដីកាសម្រេចច្រានចោល ឬលើកចោលបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។ ប៉ុន្តែមេធាវីតំណាងសិទ្ធិឱ្យភាគីអាចពន្យាអំឡុងពេលសម្រាប់បណ្តឹងសាទុក្ខនេះបាន ដោយមានមូលហេតុសមស្រប ឬតាមបញ្ញត្តិច្បាប់ដោយលិខិតជាលាយល័ក្ខណ៍អក្សរ ឬផ្ទាល់មាត់កាលបើពុំ

133 មាត្រា ១៩៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

134 មាត្រា ២៤៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

អាចជៀសវាងបាន។ ដោយអំឡុងពេលគិតរាប់ក្រោយពីមូលហេតុត្រូវបានបញ្ចប់ ១សប្តាហ៍ នៅក្នុងប្រទេស និង ២ខែ ចំពោះភាគីដែលនៅបរទេស ។[135]

### គ.៣. បណ្តឹងទាស់

បណ្តឹងទាស់ គឺជាវិធីប្តឹងចំពោះសាលក្រមកំបាំងមុខ ។[136] ត្រង់ចំណុចនេះ មានន័យថា ក្នុងករណីដែលភាគីមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ក្រោមមូលហេតុដែលមិនអាចព្យាករបាន ឬហេតុដែលមិនអាចជៀសវាងបាន មេធាវីតំណាងសិទ្ធិឱ្យភាគីដែលអវត្តមាននៅពេលជំនុំជម្រះនោះ អាចដាក់ពាក្យបណ្តឹងទាស់ ក្នុងអំឡុងពេល ២ សប្តាហ៍ ក្រោយពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ ហើយអំឡុងពេលនេះ គឺពុំអាចពន្យាបានឡើយ។[137]

### គ.៤. បណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាវិធីប្រឆាំងនឹងដីកាសម្រេច ដែលទាមទារលើកបញ្ហាក់ពីកំហុសនីតិវិធី កំហុសអង្គហេតុ កំហុសអង្គច្បាប់។ បណ្តឹងជំទាស់ អាចធ្វើទៅកើតលុះត្រាតែមានបញ្ញត្តិក្នុងច្បាប់។ មួយវិញទៀត ក្នុងករណីដែលមានដីកាសម្រេចលើបណ្តឹងជំទាស់នោះ ភាគីមិនអាចប្តឹងជំទាស់បានទៀតឡើយ។ អំឡុងពេលសម្រាប់ប្តឹងជំទាស់ ត្រឹម ១ សប្តាហ៍ ក្រោយថ្ងៃដែលបានទទួលដំណឹងពីដីកាសម្រេច ដោយអំឡុងពេលនេះ ភាគីមិនអាចព្យាពេលបានឡើយ ។[138]

### គ.៥. បណ្តឹងតវ៉ា

បណ្តឹងតវ៉ា គឺជាវិធីប្តឹងរទាមទាររបស់កូនបំណុល ឬតតិយជន ដើម្បីតតាំងទៅតុលាការអនុវត្ត ចំពោះការអនុវត្តដោយបង្ខំ ឬការចាត់ចែងរក្សាការពាររបស់ម្ចាស់បំណុលនៃការអនុវត្ត ។[139] ត្រង់ចំណុចនេះ កាលបើករណីដែលលក្ខខណ្ឌច្បាប់ត្រូវបានបំពេញ មេធាវីតំណាងសិទ្ធិឱ្យកូនបំណុលនៃការអនុវត្ត អាចស្នើកុំឱ្យតុលាការអនុវត្តដោយបង្ខំបាន។ រីឯមេធាវីតំណាងសិទ្ធិឱ្យតតិយជន គប្បីដាក់ពាក្យសុំឱ្យផ្អាកការអនុវត្តមួយរយៈ ឬពាក្យសុំលុបចោលការអនុវត្តរួមគ្នាជាមួយបណ្តឹងតវ៉ា ដើម្បីធានាដល់សិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ដែលជាកម្មវត្ថុនៃការអនុវត្តនោះសិន។ ពុំនោះទេ តតិយជន ឬកូនបំណុលនៃការអនុវត្ត គឺនត្ថិភាពនៃសិទ្ធិ

---

135 មាត្រា ២៨៦ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

136 មាត្រា ២០៤ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

137 មាត្រា ២០៤ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

138 មាត្រា ៣០៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

139 មាត្រា ៣៦៣ និងមាត្រា ៣៦៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

កាន់កាប់ ឬសិទ្ធិផ្សេងទៀតលើវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ឬការចាត់ចែងរក្សាការពារនោះហើយ។

### ២.៣.២. តួនាទីក្នុងពន្យល់ដល់កូនក្តីអំពីសិទ្ធិធ្វើបណ្តឹងសុំអនុវត្តសាលក្រម

នៅពេលដែលតុលាការចេញសាលក្រមរួចហើយ គូភាគីព្រមទទួលសេចក្តីសម្រេចនោះ គេត្រូវធ្វើការដាក់ពាក្យស្នើសុំអនុវត្តសាលក្រមដែលបានចេញមកនោះ។ ត្រង់ចំណុចនេះ មេធាវីត្រូវជួយកូនក្តីរបស់ខ្លួនក្នុងការសរសេរ និងដាក់ពាក្យស្នើសុំអនុវត្តសាលក្រមដែលតុលាការបានចេញនោះ ដើម្បីអាចទទួលបាននូវផលប្រយោជន៍ជាក់ស្តែងចំពោះកូនក្តីរបស់ខ្លួនពិតប្រាកដមែន។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក មេធាវីគឺជាបុគ្គលដែលមានចំណេះដឹងខ្ពស់ខាងផ្នែកច្បាប់ និងមានសមត្ថភាពជំនាញខាងប្រឹក្សាផ្តល់យោបល់ដូចដែលបានបកស្រាយខាងលើ ទាំងក្នុងបណ្តឹងព្រហ្មទណ្ឌ និងបណ្តឹងរដ្ឋប្បវេណី និងអាចប្រើប្រាស់សិទ្ធិតំណាងឱ្យកូនក្តីរបស់ខ្លួនក្នុងតុលាការតាមរយៈលិខិតប្រគល់សិទ្ធិ បន្ទាប់មកមេធាវីអាចអនុវត្តភារកិច្ចរបស់ខ្លួនក្នុងនីតិវិធីមុនពេលជំនុំជម្រះ ក្នុងពេលជំនុំជម្រះ និងក្រោយពេលជំនុំជម្រះ ដែលការអនុវត្តភារកិច្ចរបស់មេធាវីគឺច្បាប់ផ្តល់ឱ្យនូវសិទ្ធិពេញលេញដើម្បីធានាដល់ការប្រតិបត្តភារកិច្ច និងមធ្យោបាយរបស់ខ្លួនដោយសេរីប្រកបដោយប្រត្យក្សភាព។

ដោយឡែក មេធាវីដែលតំណាងសិទ្ធិឱ្យកូនក្តីរបស់ខ្លួនក្នុងរឿងក្តីព្រហ្មទណ្ឌ មានតួនាទីការពារសិទ្ធិដល់ជនជាប់សង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ អាស្រ័យតាមដំណាក់កាលនីមួយៗនៃនីតិវិធីតុលាការរួមមាន មេធាវីអាចសន្ទនាដោយសម្ងាត់ជាមួយជនដែលត្រូវបានឃាត់ខ្លួន និងសាកសួរទៅចៅក្រមស៊ើបសួរដើម្បីធ្វើការស៊ើបអង្កេតឬកោសល្យវិច្ច័យលើភស្តុតាងដែលបានរកឃើញ រីឯភស្តុងតាងដែលមេធាវីបានរកឃើញត្រូវបង្ហាញនៅចំពោះមុខចៅក្រមដើម្បីពិនិត្យ និងពិចារណាផងដែរ។ ចំណែកឯ មេធាវីដែលតំណាងសិទ្ធិឱ្យកូនក្តីរបស់ខ្លួនក្នុងរឿងក្តីរដ្ឋប្បវេណីវិញ ត្រូវរៀបចំបែបបទដាក់ឯកសារត្រៀម ស្វែងរកភស្តុតាងនៃអង្គហេតុសម្រាប់ដាក់ការពារ ឬតទល់ចំពោះភាគីម្ខាងទៀតដែលប្រើប្រាស់សិទ្ធិដោយបំពាន និងលើកឡើងនូវអង្គច្បាប់ដើម្បីការពារសិទ្ធិ និងកាតព្វកិច្ចជូនកូនក្តីរបស់ខ្លួនចាប់ពីនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ ដល់នីតិវិធីទាញហេតុផលផ្ទាល់មាត់ និងពន្យល់ពីសិទ្ធិដែលកូនក្តីរបស់ខ្លួនមាននៅក្រោយពេលជំនុំជម្រះផងដែរ។

បន្ថែមពីនេះទៀត ក្នុងរឿងក្តីរដ្ឋប្បវេណីមេធាវីត្រូវបានចូលរួមយ៉ាងសកម្មក្នុងការផ្សះផ្សាជាមួយភាគីម្ខាងទៀតតាមឆន្ទៈកូនក្តីខ្លួន នៅមុនពេលជំនុំជម្រះ និងក្នុងពេលជំនុំជម្រះដើម្បីរក្សាផលប្រយោជន៍ដូចជាប្រាក់ និងពេលវេលាដែលត្រូវចំណាយទៅលើដំណើរនីតិវិធីតុលាការ ក៏ដូចជាចូលរួមប្រតិបត្តិតាមគោលនយោបាយនៃការដោះស្រាយការកកស្ទះសំណុំរឿងឱ្យទទួលបានប្រសិទ្ធិភាពខ្ពស់ជាដើម។

ជាមួយគ្នានេះដែរ មេធាវីគឺបំពេញតួនាទីយ៉ាងជិតស្និតជាមួយនឹងស្ថាប័នតុលាការក្នុងការស្វែងរកភស្តុតាងដើម្បី ផ្តល់ជាមូលដ្ឋានក្នុងការត្រិះរិះពិចារណាដល់ចៅក្រមក្នុងការសម្រេចដាក់កម្រិតទណ្ឌកម្មចំពោះបុគ្គលដែលប្រើប្រាស់សិទ្ធិរបស់ខ្លួនបំពាននឹងបទប្បញ្ញត្តិច្បាប់ប្រកបដោយប្រត្យក្សភាព តម្លាភាព គណនេយ្យភាព និងយុត្តិធម៌។ ជាពិសេស ដើម្បីចូលរួមលើកស្ទួយវិស័យយុត្តិធម៌ នីតិរដ្ឋ និងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជាឱ្យកើនឡើងជាអតិបរមានូវការរៀបសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិភាព និងការរីកចម្រើនទាំងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងយុត្តិធម៌ជាដរាប។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវ អំពីសិទ្ធនិងតួនាទីរបស់មេធាវីក្នុងសាលាជម្រះក្តីជាន់ទាបរួចមកក្រុមខ្ញុំបាទ បានសង្កេតឃើញថាសិទ្ធិនិងតួនាទីរបស់មេធាវីពិតជាមានសារៈសំខាន់ណាស់ក្នុងការជម្រុញនិងអនុវត្តច្បាប់ឲ្យកាន់តែមានភាពប្រសើរឡើង។ ជាមួយគ្នានោះផងដែរក្រុមខ្ញុំបាទបានយល់ឃើញថាមានចំណុចមួយចំនួនដែលជួយជម្រុញឲ្យដំណើរការនៅក្នុងការអនុវត្តសិទ្ធិនិងតួនាទីរបស់មេធាវីឲ្យកាន់តែមានភាពល្អប្រសើរជាងពេលបច្ចុប្បន្ននេះ មានរៀបរាប់ដូចខាងក្រោម៖

❖ មេធាវីកើតចេញមកពីភាពត្រឹមត្រូវ យុត្តិធម៌ ហេតុនេះហើយការជ្រើសរើសមេធាវីមកបណ្តុះបណ្តាលក៏ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសដោយសុក្រឹត និងយុត្តិធម៌ ដើម្បីធ្វើយ៉ាងណាឲ្យការជ្រើសរើសនោះទទួលបាននូវអ្នកដែលមានសមត្ថភាពពិតប្រាកដ។ មិនត្រឹមតែប៉ុណ្ណោះ ចំពោះមេធាវីដែលអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈតាមរយៈការស្នើសុំក៏ត្រូវធ្វើឡើងប្រកបដោយភាពត្រឹមត្រូវ និងគោរពទៅតាមលក្ខខណ្ឌនានាដែរច្បាប់បានកំណត់។

❖ ការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី គឺត្រូវតែធានាបាននូវប្រសិទ្ធភាព គុណភាពចំណេះដឹង ព្រមទាំងចូលរួមបណ្តុះបណ្តាលសីលធម៌វិជ្ជាជីវៈថែមទៀតផង។ មិនតែប៉ុណ្ណោះមេធាវីខ្លួនឯងក៏ត្រូវមានការខិតខំប្រឹងប្រែងរៀនសូត្រ និងស្វែងយល់បន្ថែមឲ្យបានច្រើនដើម្បីយកមកអភិវឌ្ឍខ្លួន និងជាផ្នែកមួយនៃការជួយអភិវឌ្ឍសង្គមជាតិថែមទៀតផង។ ជាពិសេសមេធាវីមិនត្រូវភ្លេចប្រតិបត្តនូវក្រមសីលធម៌វិជ្ជាជីវៈ និងរក្សានូវគុណតម្លៃដូចជា ត្រូវមានសុចរិតភាព និងភាពស្មោះត្រង់ចំពោះអតិថិជនរបស់ខ្លួន។

❖ មេធាវីក៏ត្រូវយល់ដឹងឲ្យបានច្បាស់ពីនីតិវិធីតុលាការ និងដំណើរការរឿងក្តីមិនថារឿងក្តីអ្វីទេ ជាពិសេសក្នុងរឿងក្តីព្រហ្មទណ្ឌ និងក្នុងរឿងក្តីរដ្ឋប្បវេណី មេធាវីត្រូវយកចិត្តទុកដាក់សហការ និង ត្រូវបំពេញតួនាទីឲ្យបានល្អសម្រាប់កូនក្តីទៅតាមដំណាក់កាលនៃនីតិវិធីនីមួយៗឲ្យបានត្រឹមត្រូវ ។ មេធាវីមិនត្រូវបង្កឲ្យកើតមានកំហុសដែលនាំឲ្យនីតិវិធីតុលាការមានការយឺតយ៉ាវ ជាពិសេសធ្វើឲ្យខូចខាតប្រយោជន៍ដល់កូនក្តីរបស់ខ្លួន។

❖ នៅពេលធ្វើការផ្សះផ្សារវាងគូភាគី ទាំងការផ្សះផ្សាដោយមេធាវី និងការផ្សះផ្សាដោយតុលាការ មេធាវីត្រូវខិតខំពន្យល់ណែនាំឲ្យអស់ពីសមត្ថភាព និងសម្របសម្រួលដល់គូភាគីឲ្យមានការសះជានឹងគ្នា ដើម្បីអាចរក្សាបាននូវផលប្រយោជន៍ដល់គូភាគីទាំងសងខាង។

❖ មេធាវីត្រូវខិតខំឱ្យអស់ពីសមត្ថភាពក្នុងការស្វែងរក និងប្រមូលភស្តុតាងដាក់ទៅតុលាការដើម្បីគាំទ្រលើអំណះអំណាងរបស់ខ្លួនដែលបានលើកឡើង ដើម្បីអាចការពារបាននូវផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន។ ម្យ៉ាងវិញទៀត មេធាវីមិនត្រូវប្រើមធ្យោបាយទុច្ចរិត ឬខុសច្បាប់ណាមួយដើម្បីឱ្យបានឈ្នះក្តីនោះឡើយ។

# ឯកសារយោង

# ឯកសារយោង

## ❖ ច្បាប់

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ក្រមសីលធម៌មេធាវី ឆ្នាំ២០១២
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥
- បទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៥
- គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ឆ្នាំ១៩៩០

ប្រភព: https://cambodia.ohchr.org/sites/default/files/book/AdminofJustice-KH.pdf

## ❖ អនុក្រឹត្យ

- អនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

## ❖ សេចក្តីសម្រេច

- សេចក្តីសម្រេចពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ ឆ្នាំ២០១៧
- សេចក្តីសម្រេចស្តីពី នីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ឆ្នាំ ២០២១

## ❖ អត្ថបទស្រាវជ្រាវ

- អត្ថបទ "តួនាទី និងភារកិច្ចរបស់មេធាវីនៅប្រទេសកម្ពុជា" ស្រាវជ្រាវដោយ កញ្ញា ហេង នីដា, កញ្ញា ជា សុគន្ធមិនា និងលោកស្រី វ៉ាន់ ណារី ឆ្នាំ២០១៧
- អត្ថបទ "តួនាទីរបស់មេធាវី" ស្រាវជ្រាវដោយ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ
- អត្ថបទ "នីតិវិធីជំនុំជម្រះក្តីលើកទី១" រៀបរៀងដោយលោកមេធាវី ប៉ោ ហ៊ុយ ឆ្នាំ២០១៩

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៨៩៥ / ០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០១០៥ / ០១៩ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និង សុក្រឹតការវិជ្ជាជីវៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨

## ស ម្រេ ច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត **មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី** សរសេរកាត់ថា **ម.ប.វ.ម** ។

**មាត្រា ២.-**

**ម.ប.វ.ម** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវ ផ្នែកបច្ចេកទេស ដោយផ្ទាល់ពីក្រុមប្រឹក្សាគណៈមេធាវី និងផ្នែករដ្ឋបាល ដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

**មាត្រា ៣.-**

ផ្នែករដ្ឋបាលដែលបានកំណត់ក្នុងមាត្រា ២ រួមមាន: ការគាំពារលើអគារ បន្ទប់សិក្សា សម្ភារបរិក្ខារសិក្សា សន្តិសុខ និងសណ្តាប់ធ្នាប់ នៅក្នុងបរិវេណនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

**មាត្រា ៤.-**

**ម.ប.វ.ម** ត្រូវមានបទបញ្ជាផ្ទៃក្នុងមួយ ដែលកំណត់នូវលក្ខខណ្ឌក្នុងដំណើរការការងាររបស់ខ្លួន ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ។

### ជំពូកទី ២
### តួនាទី និង ភារកិច្ច

**មាត្រា ៥.-**

**ម.ប.វ.ម** មានតួនាទី និង ភារកិច្ចដូចខាងក្រោម:

- រៀបចំសេចក្តីព្រាងនីតិវិធីប្រឡងជ្រើសរើសឱ្យចូលរៀននៅ **ម.ប.វ.ម** និងប្រឡងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី
- រៀបចំកម្មវិធីសិក្សា និង ការជ្រើសរើសគ្រូបណ្តុះបណ្តាល ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច

- ធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីដល់សិស្សមេធាវី បណ្តុះបណ្តាលបន្ថែមដល់មេធាវីកម្មសិក្សា រៀបចំវគ្គសិក្ខាសាលា ដល់មេធាវីដែលកំពុងប្រកបវិជ្ជាជីវៈ
- ធ្វើរបាយការណ៍សកម្មភាព និង របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាសជូនក្រុមប្រឹក្សាគណៈមេធាវី
- ធ្វើសកម្មភាពផ្សេងៗទៀតតាមការសម្រេចចាត់តាំងដោយក្រុមប្រឹក្សាគណៈមេធាវី ។

## ជំពូកទី ៣
## ការប្រឡងជ្រើសរើសសិស្សមេធាវី និង ការបណ្តុះបណ្តាល

**មាត្រា ៦.-**

ការកំណត់ចំនួនសិស្សមេធាវី នីតិវិធីនៃការប្រឡងជ្រើសរើសសិស្សមេធាវី កម្មវិធីបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងការប្រឡងយកវិញ្ញាបនបត្រសមត្ថភាពខាងវិជ្ជាជីវៈមេធាវី ត្រូវពិនិត្យសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ។

**មាត្រា ៧.-**

បេក្ខជនដែលប្រឡងចូល ម.ប.ទ.ម ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម :

- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានបរិញ្ញាបត្រច្បាប់ ឬ សញ្ញាបត្រច្បាប់ ដែលបានប្រកាសថាមានតម្លៃសមមូល
- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬ ឧក្រិដ្ឋ ឬ ផ្តន្ទាទោសជាបទវិន័យ ឬ ផ្តន្ទាទោសជាបទរដ្ឋបាល ដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហួតងារអំពីអំពើផ្ទុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួន ដែលប្រកាសដោយតុលាការ
- ត្រូវមានសីលធម៌ និង កាយសម្បទាគ្រប់គ្រាន់ ។

**មាត្រា ៨.-**

គណៈមេប្រយោគសម្រាប់ប្រឡងជ្រើសរើសសិស្សមេធាវី និងការប្រឡងយកវិញ្ញាបនបត្រសមត្ថភាពខាងវិជ្ជាជីវៈមេធាវី ត្រូវមានសមាសភាពចំនួន ៩រូប ដូចខាងក្រោម :

- ប្រធានគណៈមេធាវី ប្រធាន
- តំណាងក្រសួងយុត្តិធម៌ ១រូប អនុប្រធាន

- សមាជិកក្រុមប្រឹក្សាគណៈមេធាវី ៤រូប សមាជិក
- នាយក ម.ប.ទ.ម សមាជិក
- តំណាងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ១រូប សមាជិក
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក

**មាត្រា ៩.-**

សិស្សមេធាវី ត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីឱ្យបានពេញលេញតាមកម្មវិធីសិក្សា ដែលត្រូវកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវី ។

សិស្សមេធាវីដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យត្រូវទទួលបានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ដែលចេញដោយ **ម.ប.ទ.ម** និងមានការទទួលស្គាល់ពីគណៈមេធាវី ។

ក្នុងរយៈពេលបណ្តុះបណ្តាលសិស្សមេធាវី នឹងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ តាមការកំណត់របស់រដ្ឋ ។

## ជំពូកទី ៤

## ធនធានហិរញ្ញវត្ថុ

**មាត្រា ១០.-**

**ម.ប.ទ.ម** មានថវិកាដែលផ្គត់ផ្គង់ដោយរដ្ឋ សម្រាប់អនុវត្តការងាររបស់ខ្លួន ដែលថវិកានោះត្រូវស្ថិតក្នុងកញ្ចប់ថវិការបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

**ម.ប.ទ.ម** មានធនធាន និងថវិកាដោយឡែកដែលបានមកពីប្រភពផ្សេងៗទៀតដូចខាងក្រោម :

- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ការចុះឈ្មោះរបស់បេក្ខជនប្រឡងចូលរៀនវិជ្ជាជីវៈមេធាវី
- ចំណូលក្នុងការសុំចុះឈ្មោះចូលរៀនរបស់សិស្សមេធាវី
- ការបង់ថ្លៃបណ្តុះបណ្តាល សុក្រឹតការវិជ្ជាជីវៈមេធាវី និង ការអប់រំបន្ត
- ការចុះឈ្មោះរបស់មេធាវីកម្មសិក្សា ដែលត្រូវធ្វើសុក្រឹតការវិជ្ជាជីវៈមេធាវី
- ជំនួយ និង ប្រាក់ឧបត្ថម្ភពីស្ថាប័នជាតិ អន្តរជាតិ និង ពីសហគមន៍នានា ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

អនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និង សុក្រឹតការវិជ្ជាជីវៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានគណៈមេធាវី ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០៨*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

## ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

លេខ ៖..........................

យើង..............................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាខេត្តកណ្ដាល

បានឃើញមាត្រា ៦២ កឋាខ័ណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ:.....................ចុះថ្ងៃទី..........ខែ...........ឆ្នាំ..........របស់សាលាដំបូងខេត្តកណ្ដាល ។

រវាងដើមចោទឈ្មោះ..........................ភេទ..........អាយុ......ឆ្នាំ របរកស៊ី...............................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ..............ផ្លូវលេខ......................ក្រុម..............ភូមិ................................
ឃុំ,សង្កាត់.................................ស្រុក, ខណ្ឌ.................................ខេត្ត, ក្រុង...............................
ប្ដី, ប្រពន្ធឈ្មោះ..................................... មានកូន................នាក់។

និងចុងចំលើយឈ្មោះ..............................ភេទ........... អាយុ.........ឆ្នាំ របរកស៊ី.......................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ផ្លូវលេខ..................ក្រុម............ភូមិ....................................
ឃុំ, សង្កាត់................................ស្រុក, ខណ្ឌ................................ខេត្ត, ក្រុង..................................
ប្ដី, ប្រពន្ធឈ្មោះ.................................... មានកូន...............នាក់។

ដែលមានកម្មវត្ថុបណ្ដឹង:.......................................................................................................
.......................................................................................................................................

### សំអាងហេតុ

-ដើម្បីដំណើរការនីតិវិធីបណ្ដឹងទៅតាមច្បាប់។

-..........................................................................................................................

-..........................................................................................................................

### ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យដើមចោទឈ្មោះ.................................មានទីលំនៅផ្ទះលេខ...........ផ្លូវលេខ.............
ក្រុម.............ភូមិ............................ឃុំ, សង្កាត់..............................ស្រុក, ខណ្ឌ..............................
ខេត្ត, ក្រុង.........................................។
បង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធចំនួន...........................................................................
នៅសាលាដំបូងខេត្តកណ្ដាល ឱ្យបានមុនថ្ងៃទី....................ខែ...................ឆ្នាំ................... ជាកំណត់ដើម្បីតុលាការចាត់ការរឿងក្ដីនេះតាមច្បាប់ ។

បានទទួល
ថ្ងៃទី.........ខែ................ឆ្នាំ............
**ស្នាមមេដៃ**

កណ្ដាល, ថ្ងៃទី............ខែ...........ឆ្នាំ............
**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

# ដីកាសម្រេចបណ្តឹងជិតចិត្ត

លេខ:............................

យើង......................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរៈ នៃសាលាដំបូងខេត្តកណ្តាល

បានឃើញមាត្រា ៣០ និងមាត្រា៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ:......................ចុះថ្ងៃទី...........ខែ............ឆ្នាំ...........របស់សាលាដំបូងខេត្តកណ្តាល ។

រវាងដើមចោទឈ្មោះ..........................ភេទ...........អាយុ.......ឆ្នាំ របរកស៊ី................................ មានទីលំនៅសព្វថ្ងៃផ្ទះលេខ..............ផ្លូវលេខ......................ក្រុម..............ភូមិ................................ ឃុំ,សង្កាត់.................................ស្រុក, ខណ្ឌ..................................ខេត្ត, ក្រុង.............................. ប្តី, ប្រពន្ធឈ្មោះ...................................... មានកូន.................នាក់។

និងចុងចំលើយឈ្មោះ.............................ភេទ........... អាយុ.........ឆ្នាំ របរកស៊ី....................... មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ផ្លូវលេខ..................ក្រុម............ភូមិ.................................... ឃុំ, សង្កាត់................................ស្រុក, ខណ្ឌ................................ខេត្ត, ក្រុង.................................. ប្តី, ប្រពន្ធឈ្មោះ..................................... មានកូន................នាក់។

ដែលមានកម្មវត្ថុបណ្តឹង:.............................................................................................. ..........................................................................................................................................

បានឃើញពាក្យបណ្តឹងជិតចិត្តរបស់ឈ្មោះ.....................................................ចំពោះចៅក្រម, ក្រឡាបញ្ជីឈ្មោះ.................................ដោយមូលហេតុ.......................................................... ..........................................................................................................................................

## សំអាងហេតុ

-..............................................................................................................................

-..............................................................................................................................

-..............................................................................................................................

## ហេតុដូច្នេះសម្រេច

១-ទទួលពាក្យបណ្តឹងជិតចិត្តចៅក្រម, ក្រឡាបញ្ជីឈ្មោះ................................មានមូលហេតុ ពុំត្រឹមត្រូវតាមច្បាប់។

២-ដក, ឱ្យចៅក្រម, ក្រឡាបញ្ជី ដែលទទួលកិច្ចការសំណុំរឿងនេះចេញ, ចាត់ការតទៅទៀត។

កណ្តាល, ថ្ងៃទី...........ខែ.............ឆ្នាំ............

**ក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

## ដីកាសម្រេចជ្រើសតាំង ឬផ្លាស់ប្តូរអ្នកតំណាងពិសេស

លេខ:............................

យើង........................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងខេត្តកណ្ដាល

បានឃើញមាត្រា ៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ:.....................ចុះថ្ងៃទី..........ខែ...........ឆ្នាំ..........របស់សាលាដំបូងខេត្តកណ្ដាល ។

រវាងដើមចោទឈ្មោះ..........................ភេទ..........អាយុ......ឆ្នាំ របរកស៊ី...............................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ..............ផ្លូវលេខ.....................ក្រុម..............ភូមិ................................
ឃុំ,សង្កាត់.................................ស្រុក, ខណ្ឌ..................................ខេត្ត, ក្រុង...............................
ប្តី, ប្រពន្ធឈ្មោះ..................................... មានកូន................នាក់។

និងចុងចំលើយឈ្មោះ.............................ភេទ........... អាយុ.........ឆ្នាំ របរកស៊ី......................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ផ្លូវលេខ.................ក្រុម............ភូមិ...................................
ឃុំ, សង្កាត់................................ស្រុក, ខណ្ឌ................................ខេត្ត, ក្រុង..................................
ប្តី, ប្រពន្ធឈ្មោះ.................................... មានកូន...............នាក់។

ដែលមានកម្មវត្ថុបណ្តឹង:............................................................................................................
..........................................................................................................................................

បានឃើញពាក្យសុំជ្រើសរើស, ផ្លាស់ប្តូរអ្នកតំណាងចុះថ្ងៃទី.....................................................
របស់ឈ្មោះ................................ភេទ.............អាយុ...........ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះលេខ...........
ផ្លូវលេខ..................ក្រុម........ភូមិ.........................................ឃុំ, សង្កាត់.........................................
ស្រុក, ខណ្ឌ...........................................ខេត្ត, ក្រុង.................................... ។

### សំអាងហេតុ

-..........................................................................................................................
-..........................................................................................................................
-..........................................................................................................................

### ហេតុដូច្នេះសម្រេច

ជ្រើសតាំង, ផ្លាស់ប្តូរ ឈ្មោះ................................អាយុ...............ឆ្នាំ មានអាស័យដ្ឋានខាងលើជាតំណាងពិសេសឱ្យឈ្មោះ................................ចាប់ពីពេលនេះតទៅ ។

កណ្ដាល, ថ្ងៃទី..........ខែ............ឆ្នាំ............

**ក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

## ដីកាសម្រេចជ្រើសតាំង ឬផ្លាស់ប្តូរអ្នកតំណាងពិសេស

លេខ:............................

យើង........................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងខេត្តកណ្តាល

បានឃើញមាត្រា ៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ:.....................ចុះថ្ងៃទី..........ខែ...........ឆ្នាំ..........របស់សាលាដំបូងខេត្តកណ្តាល ។

រវាងដើមចោទឈ្មោះ..........................ភេទ..........អាយុ......ឆ្នាំ របរកស៊ី...............................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ..............ផ្លូវលេខ......................ក្រុម..............ភូមិ...............................
ឃុំ,សង្កាត់.................................ស្រុក, ខណ្ឌ.................................ខេត្ត, ក្រុង...............................
ប្តី, ប្រពន្ធឈ្មោះ..................................... មានកូន................នាក់។

និងចុងចំលើយឈ្មោះ............................ភេទ........... អាយុ.........ឆ្នាំ របរកស៊ី......................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ផ្លូវលេខ..................ក្រុម............ភូមិ....................................
ឃុំ, សង្កាត់................................ស្រុក, ខណ្ឌ...............................ខេត្ត, ក្រុង..................................
ប្តី, ប្រពន្ធឈ្មោះ.................................... មានកូន...............នាក់។

ដែលមានកម្មវត្ថុបណ្តឹង:..........................................................................................................
.............................................................................................................................................

បានឃើញពាក្យសុំជ្រើសរើស, ផ្លាស់ប្តូរអ្នកតំណាងចុះថ្ងៃទី.....................................................
របស់ឈ្មោះ................................ភេទ.............អាយុ...........ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះលេខ...........
ផ្លូវលេខ..................ក្រុម........ភូមិ...........................................ឃុំ, សង្កាត់........................................
ស្រុក, ខណ្ឌ...............................................ខេត្ត, ក្រុង.................................... ។

### សំអាងហេតុ

-.........................................................................................................................
-.........................................................................................................................
-.........................................................................................................................

### ហេតុដូច្នេះសម្រេច

ជ្រើសតាំង, ផ្លាស់ប្តូរ ឈ្មោះ................................អាយុ..............ឆ្នាំ មានអាស័យដ្ឋានខាងលើជាតំណាងពិសេសឱ្យឈ្មោះ.................................ចាប់ពីពេលនេះតទៅ ។

កណ្តាល, ថ្ងៃទី..........ខែ............ឆ្នាំ............

**ក្រុមប្រឹក្សាជំនុំជំរះ**

........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................

| | |
|---|---|
| **ក្រឡាបញ្ជី** | **ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
| ហត្ថលេខា | ហត្ថលេខា |

សាលាដំបូងក្រុងភ្នំពេញ

លេខ:

------------------------

........................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ដីកាសម្រេចបង្គាប់ឱ្យនាំខ្លួនសាក្សី

យើង.................................. ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងក្រុងភ្នំពេញ។

បានឃើញមាត្រា ១៣២ កឋាខ័ណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យ ប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ:....................ចុះថ្ងៃទី..........ខែ...........ឆ្នាំ..........របស់ សាលាដំបូងខេត្តកណ្ដាល ។

រវាងដើមចោទឈ្មោះ..........................ភេទ..........អាយុ......ឆ្នាំ របរកស៊ី................................ មានទីលំនៅសព្វថ្ងៃផ្ទះលេខ.............ផ្លូវលេខ.....................ក្រុម.............ភូមិ.................................. ឃុំ,សង្កាត់.................................ស្រុក, ខណ្ឌ...................................ខេត្ត, ក្រុង............................... ប្ដី, ប្រពន្ធឈ្មោះ..................................... មានកូន................នាក់។

និងចុងចំលើយឈ្មោះ..............................ភេទ........... អាយុ........ឆ្នាំ របរកស៊ី....................... មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ផ្លូវលេខ..................ក្រុម............ភូមិ...................................... ឃុំ, សង្កាត់................................ស្រុក, ខណ្ឌ...............................ខេត្ត, ក្រុង.................................. ប្ដី, ប្រពន្ធឈ្មោះ.................................... មានកូន...............នាក់។

ដែលមានកម្មវត្ថុបណ្ដឹង:.........................................................................................................
..........................................................................................................................................

បានឃើញ......................................................................................................................

### សំអាងហេតុ

-..................................................................................................................................

-..................................................................................................................................

-..................................................................................................................................

### ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យនាំខ្លួនសាក្សីឈ្មោះ.............................. ភេទ.......... អាយុ..........ឆ្នាំ របររកស៊ី ..................... មានទីលំនៅសព្វថ្ងៃផ្ទះលេខ.............. ផ្លូវ...................... ក្រុម........... ភូមិ...............ឃុំ, សង្កាត់...................... ស្រុក,ខណ្ឌ.......................... ខេត្ត,ក្រុង.......................... មកចំពោះមុខ ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ នៃសាលា ដំបូងក្រុងភ្នំពេញ នៅថ្ងៃទី......... ខែ..................... ឆ្នាំ ................ វេលាម៉ោង..................។

ធ្វើនៅក្រុងភ្នំពេញ, ថ្ងៃទី........... ខែ............ឆ្នាំ............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
លេខ:
........................

# ដីកាសម្រេចបង្គាប់ឱ្យធ្វើការទាញហេតុផល
# ដោយផ្ទាល់មាត់សាជាថ្មី

យើង...................................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញមាត្រា ១៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.................. ចុះថ្ងៃទី......... ខែ.............ឆ្នាំ........... របស់សាលាដំបូងរាជធានីភ្នំពេញ។

រវាងដើមចោទឈ្មោះ......................ភេទ........... អាយុ.........ឆ្នាំ របរកស៊ី................................ មានទីលំនៅសព្វថ្ងៃផ្ទះលេខ........... ផ្លូវលេខ....... ក្រុម........ភូមិ................... ឃុំ, សង្កាត់................... ស្រុក, ខណ្ឌ.................... ខេត្ត, ក្រុង..................... ប្ដី, ប្រពន្ធឈ្មោះ................. មានកូន..........នាក់។

និងចុងចំលើយឈ្មោះ......................ភេទ........... អាយុ.........ឆ្នាំ របរកស៊ី................................ មានទីលំនៅសព្វថ្ងៃផ្ទះលេខ........... ផ្លូវលេខ....... ក្រុម........ភូមិ................... ឃុំ, សង្កាត់................... ស្រុក, ខណ្ឌ.................... ខេត្ត, ក្រុង..................... ប្ដី, ប្រពន្ធឈ្មោះ................. មានកូន..........នាក់។

ដែលមានកម្មវត្ថុបណ្ដឹង:....................................................................................................
.................................................................................................................................

បានឃើញដំណើរការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី........ ខែ................. ឆ្នាំ........... នៅសាលា ដំបូងរាជធានីភ្នំពេញ។

## សំអាងហេតុ

-...........................................................................................................................
-...........................................................................................................................
-...........................................................................................................................

## ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យធ្វើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មី លើសំណុំរឿងរដ្ឋប្បវេណីលេខ........... ចុះថ្ងៃទី.... ខែ................. ឆ្នាំ............ នៅសាលាដំបូងរាជធានីភ្នំពេញ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ............ឆ្នាំ............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងក្រុងភ្នំពេញ
សំណុំរឿងរដ្ឋប្បវេណីលេខ:
.....................ចុះថ្ងៃទី
.........ខែ..................ឆ្នាំ
...............
សាលក្រមលេខ ____________

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងក្រុងភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើ
តាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី......... ខែ.................. ឆ្នាំ.............
លើសំណុំរឿងរដ្ឋប្បវេណីលេខ .................... ចុះថ្ងៃទី.......... ខែ.................. ឆ្នាំ............
ដោយមានសមាសភាពដូចតទៅ
ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ:
លោក, លោកស្រី.........................................
លោក, លោកស្រី.........................................
លោក, លោកស្រី.........................................
តំណាងអយ្យការ
លោក, លោកស្រី.........................................
ក្រឡាបញ្ជី
លោក, លោកស្រី .......................................

រវាងដើមចោទឈ្មោះ......................ភេទ........... អាយុ.........ឆ្នាំ របរកស៊ី................................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ........... ផ្លូវលេខ....... ក្រុម........ភូមិ.................... ឃុំ, សង្កាត់...................
ស្រុក, ខណ្ឌ.................... ខេត្ត, ក្រុង..................... ប្តី, ប្រពន្ធឈ្មោះ................. មានកូន..........នាក់។
អ្នកតំណាងដោយអាណត្តិ, ពិសេស លោក, លោកស្រី.............................................................
និងចុងចំលើយឈ្មោះ......................ភេទ........... អាយុ.........ឆ្នាំ របរកស៊ី..............................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ........... ផ្លូវលេខ....... ក្រុម........ភូមិ.................... ឃុំ, សង្កាត់...................
ស្រុក, ខណ្ឌ.................... ខេត្ត, ក្រុង..................... ប្តី, ប្រពន្ធឈ្មោះ................. មានកូន..........នាក់។
អ្នកតំណាងដោយអាណត្តិ, ពិសេស លោក, លោកស្រី.............................................................
ដែលមានកម្មវត្ថុបណ្តឹង:....................................................................................................
....................................................................................................................................

## អង្គហេតុ និងចំណុចវិវាទ

ទី១-សាលក្រមដែលទាមទារដោយភាគី

១-សាលក្រមដែលទាមទារដោយដើមចោទ

១-១..........................................................................................................................
....................................................................................................................................
១-២..........................................................................................................................
១-៣..........................................................................................................................

២-ចម្លើយតបរបស់ចុងចម្លើយ

២-១.......................................................................................................

